# មជ្ឈមណ្ឌលឯកសារកម្ពុជា

**TKI0748**

## *ករណី សៀន សេង ក្រៅប្រវត្តិរូប*
## *មុខងារៈ នារីពេទ្យ*
## *បទសម្ភាសន៍ជាមួយ សៀន សេង អាយុ៤៦ឆ្នាំ ត្រូវជាម្ចាស់ប្រវត្តិរូប*
## *នៅភូមិទទឹងថ្ងៃ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ*
## *នៅថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០០១*
## *សម្ភាសន៍ដោយៈ អែម សុខឃីម និងសុជល*

*ឃីមៈ* *បងកាលមុនខ្ញុំមកសម្ភាសន៍បងម្ដងហើយ ឥឡូវខ្ញុំមកសម្ភាសន៍បងបន្ថិច បងចាំពីប្រវត្តិបងតាំងពីដំបូង បងនិយាយហូរហែរបងឥឡូវបងមឿនអង្គុយស្ដាប់គាត់ម្ដង ម្ដងម្នាក់ បងកាលណឹងអាយុប៉ុន្មានគេហៅទៅ*

*សេងៈ* *ឆ្នាំ៧១ បានជាខ្ញុំចូល កាល៧០ខ្ញុំនៅរៀនតាកែវ ឆ្នាំ៧១ណឹងគេវៃបែកតាកែវ ខ្ញុំនៅជាមួយពូខ្ញុំតាកែវណឹងគេឲ្យទៅយាមកាលណឹងគាត់ធ្វើគ្រូដល់ពិបាកពេកម៉ែខ្ញុំនៅស្រែ នេះផ្ដាំឲ្យខ្ញុំមកគេលែងឲ្យទៅវិញថាជំនាន់ណឹងគេរើសនារី ខ្ញុំក៏អត់ទៅវិញដល់ពេលនោះគេ រើសនារីរែកបាយជាមួយគេណឹង ពេលទៅរែកបាយណឹងវាពិបាកដែរ រែកបាយណឹងមួយថ្ងៃគ្រាប់ញ្ជាងផងឡានហោះទំលាក់ផង២៨ថ្ងៃរែកបាយជាមួយមឿនណឹង មឿនគេត្រូវរបួសខ្ញុំនៅតូចជាងគេ អាយុ១៦ខ្ញុំអត់មានត្រូវរបួសអីទេ មកដល់គេថា រែក បាយ បើត្រូវរបួសហើយអត់ជួយយកគ្នាមកវិញទេគេថាអញ្ចឹង ខ្ញុំថាបើយកម៉េចបើទឹក ត្រឹមៗ ចង្កេះសែងម៉េចកើត គេក៏ដេញទៅវិញ ទៅវិញទៅ ខ្ញុំថាឥឡូវ កាលណឹងគណៈស្រុកគេបងខ្ញុំ គណៈស្រុកត្រាំកក់ ហើយតាសោមគណៈតំបន់ថាទៅវិញ ខ្ញុំថាអត់ទៅទេ ឥឡូវបើបងឯងក្លាហានបងឯងទៅម្ដងទៅ ខ្ញុំ២៨ថ្ងៃទៅរែក គ្មានស្គាល់បាយដេកបាយអង្គុយអីទេ អត់របួសណឹងសំណាងខ្ញុំមានហើយ ខ្ញុំថាឲ្យអញ្ចឹងដល់ហើយបានម៉ាអាទិត្យ មឿនត្រូវរបួសគេទៅដេកពេទ្យ ខ្ញុំគេហៅទៅរៀន ខ្ញុំថាឥឡូវបើរែកបាយឈប់រែកហើយបើធ្វើទព*

ធ្វើទៅសមរភូមិហ្នឹងគេថាអញ្ចឹងហ្អែងក្លាហានទៅសមរភូមិទៅក៏ទៅ គេរើសទៅទ័ព គេឲ្យទៅ ដល់ស្រុក ស្រុកគេបញ្ជូនទៅដល់តំបន់ ដល់ប្រធានតំបន់ផ្នែកតំបន់ណឹងគេស្គាល់ប្រធានផ្នែកនារីណឹង គេស្គាល់ថា ហ៊ុចុះគេឲ្យវាមកធ្វើអី វាធ្លាប់នៅជាមួយឃុំធ្វើនិរសាឃុំគេនោះ មកធ្វើអី ខ្ញុំថាអត់ទេ ខ្ញុំទៅរែកបាយហើយគេត្រូវរបួសអស់សល់តែខ្ញុំមួយគេឲ្យខ្ញុំទៅវិញ ខ្ញុំមិនទៅ ឥឡូវខ្ញុំលេងរែកបាយហើយខ្ញុំធ្វើទ័ព គេក៏កាលណឹងរើសគ្នាដូច៥០០នាក់មក ពេលនោះគេរកអ្នកសរសេរប្រវត្តិរូបអត់បាន កាលជំនាន់នោះក្រអ្នកចេះអក្សរគេឲ្យខ្ញុំជ្រើសរើសប្រវត្តិរូប រើសទ័ពម៉ាកងវរៈហើយម៉ាកងវរៈទៀតឲ្យទៅធ្វើទ័ពណឹង នៅតែឈ្មោះខ្ញុំគេអត់ឲ្យទៅ គេថា គេមិនឲ្យទៅទេ គេទុកនៅណឹង គេថាទុកចំរាញ់ព្រោះអីយើងវណ្ណៈភាពកាលណឹងគេរើស ខ្ញុំជាកូនអ្នកកណ្តាលថ្នាក់លើហើយនៅជាមួយអនុធនទៀតបញ្ញវ័ន្ត ពូខ្ញុំណឹងធ្វើគ្រូ ដល់ហើយពូខ្ញុំណឹងគាត់ចូលទៅខាងក្នុងវិញ កាលណឹងចូលទៅតាកែវវិញគេនៅ គេរែកស្មៃ នៅកាលណឹងវេទនាដែរណឹង ខោអាវគេមិនបើកឲ្យពាក់ទេ នៅណឹងបានជិតមួយឆ្នាំដើរទៅឌុបគេណឹងគេទៅណាគេឲ្យឌុបកង់ជូនគេទៅ ទៅចឹងទៅដូចអត់មានចេះអីសោះ ដូចនៅធ្វើខ្ញុំគេ ខ្ញុំថាធ្វើបដិវត្តន៍អួតថាកសាងខ្លួនឲ្យធ្វើនេះធ្វើនោះឥឡូវឲ្យធ្វើតែ ឥឡូវអត់មានខ្ញុំបំរើដូចជំនាន់សក្តិភូមិមែន ប៉ុនឲ្យធ្វើកងការពារអង្គរក្សដូចតែគ្នាណឹងខ្ញុំថាចឹង នៅតែខ្ញុំបំរើដូចតែគ្នាណឹង គេខឹងគេវាយការណ៍ទៅទៀត គេបញ្ជូនខ្ញុំទៅតំបន់៣២នៅកំពង់ស្ពឺទៅ ក្រាន់តែទៅបានឆ្នាំ៧៨ គ្រុនចាញ់នោះមហាចាញ់ហើយទៅនៅសង្កែជ្រុំណឹង ចាញ់ម៉ាថ្ងៃញាក់បីបួនដង ខ្ញុំថាដូចវេទនាណាស់ ខ្ញុំសុំធ្វើពេទ្យចង់ធ្វើពេទ្យឆ្នាំ៧៨គេឲ្យចូលទៅធ្វើពេទ្យ ចុះបើខ្លះចាក់ថ្នាំទៅមើលតែសំបកដបមើលអក្សរអត់រួចអក្សរខ្មែរខ្លះអក្សរបារាំងខ្លះប៉ុនគ្នាអត់ចេះ ខ្ញុំចេះ ចេះតែមើលខ្លះទៅ ខ្ញុំថាអត់ទេជីវិតតែមួយមកម្នាក់ឯងដងស្លាប់ទៅអ្នកណាមើល បើគេចាក់ទៅប្រតិកម្មអីសុំគេរៀនដល់ហើយគេឲ្យទៅរៀន រៀនពេទ្យឆ្នាំ៧៨ នៅជីឆ្នាំភូមិភាគបស្ចឹមពេទ្យតំបន់គេ នៅឃុំតាំងសំរោងជីឆ្នាំងពេទ្យណឹងធំណាស់ ពេទ្យតំបន់៣២ ដល់ទៅរៀនណឹង គេចេះតែសង្កត់យើងដែរណឹង គេបែកចែកវណ្ណៈអញ្ចឹងឯងចេះតែទាបជាងគេ ចេះតែអោនទៅចេះខំប្រឹងធ្វើយកចិត្តទុកដាក់ គេរៀនមុនដំបូងណឹងឲ្យរៀនចាក់ខ្នើយ ចាក់ខ្នើយហើយចាក់ដើមចេកចាក់ឈរ ចាក់ខ្នើយរៀនចាក់ត្រកៀក ដល់ចេះចាក់ណឹងហើយ គេបង្រៀបចាក់សាច់ដុំហើយអស់គេបង្រៀនចាក់សរសៃគេប្រាប់ពីរឿងចាក់សរសៃ រៀបបន្ទោងសេរ៉ូមចូលវះអីជាមួយគ្នាបានចេះច្រើនដែរណឹង ដល់

៧៥ គេយកខ្ញុំទៅភូមិភាគបស្ចឹមគេឲ្យទៅរៀន នៅពេទ្យ១៧ កាលណឹង៣១៧ពេទ្យរុស្សី គេឲ្យទៅរៀន ម៉ាំវគមុនដំបូងគេឲ្យរៀន៥ខែ រៀនជាមួយតាប៉ែនដាក់ស្ដែង តាប៉ែន ហៅ ដួន ជឿនណឹង ហើយជាមួយតាអ៊ិនសូកានឈ្មោះតានី ហើយដួន ជឿនណឹងហៅតាប៉ែន ៗ កាលពីជំនាន់នោះ ហើយពូសាគខាងទូទៅ បងថនណឹងខាងឆ្មបហើយប្រពន្ធតាដួនជឿន ណាំងមិនដឹងឈ្មោះអីទេ គាត់ខាងពិសោធន៍ កូនៗគាត់បងនាត បងអីណឹងសុទ្ធតែនៅជា មួយគ្នា បងហឿនណឹងកូនដែរ ប៉ុនឥឡូវមិនដឹងគេឈ្មោះអីដឹងរស់ឬស្លាប់ទេអត់ដឹងដែរ កាលខ្ញុំទៅរៀនណឹងមានបងសីខាងសេដ្ឋកិច្ចគេចាប់គាត់ដែរគេថាគាត់អ្នលបះបោរបេះមួយ បេះពីរកាលណឹងសិក្ខកាមច្រើនជាង២ពាន់ ដល់ហើយពេលហូបបាយអញ្ចឹងវាមាន ចុះគ្នា ច្រើនខ្វះមានរុយ ដួនកាលមានចូលអំបែងសីកអីណឹង យើងផ្ញើបន្ទៃហាន់ដាក់គ្រែដល់ស្ទួ គេចោទទៅ គេចាប់បាត់ទៅខ្ញុំក៏អត់ដឹង ខ្ញុំនៅតែរៀនណោះកាលណឹងឆ្នាំ៧៥ដើមដំបូង រៀនបានដើមឆ្នាំ កាលណឹងបែកខែ៥ ទៅរៀនមកវិញគេឲ្យទៅកសាងនៅមន្ទីរពេទ្យនៅ មន្ទីរពេទ្យមួយទៀតខ្ញុំ ទៅរៀនបាន៥ខែគេឲ្យទៅ ចុះយើងដាក់ស្ដែងយើងចុះផ្ទាល់នៅ ពេទ្យកាងពលអីហូរហែរមកដែរគេឲ្យទៅកសាងមន្ទីរពេទ្យនៅភូមិភាគបស្ចឹបអន្ទង់ជ្រៃ ស្រុក ទឹកផុសនៅក្នុងព្រៃហោងគេឲ្យទៅយកថ្នាំនៅខិវ៉ាល់ កាលណឹងឲ្យខ្ញុំនៅតែពីរនាក់កូនតាចេង អន បូរ៉ាត់កូនគាត់ នៅតែពីរនាក់ខ្ញុំបង្កើតបានមន្ទីរពេទ្យមួយក្នុងព្រៃហោងកំសត់ណាស់ យប់ឡើងខ្លាមករាល់ថ្ងៃ មានបុគ្គលិកតែ៥នាក់ទេ មុនដំបូងបង្អស់ដល់យូរទៅបង្កើតបាន ១៥០នាក់មានដុកទ័រមានតាប៉ិនមួយគាត់ដុកទ័រមកពីស្រុកបារាំងគាត់មកម្ដែឆ្នាំមកដល់នៅ ជាមួយខ្ញុំតែ៥ខែគេចាប់យកទៅបាត់ បង្កើតបានបុគ្គលិក១៥០ណឹងស្រាប់តែគេត្រូវទៅ រៀនឯកទេស គេឲ្យខ្ញុំទៅរៀនខាងឯកទេសទូទៅ ១៨នាក់ដែលយកទៅរៀនណឹងតាមមុខ សញ្ញាគ្រប់គ្នាទៅដល់ពេលទៅរៀនបានប្រហែលជា២ខែគេហៅឡាន គេហៅមកវីង កាល រៀនឯកទេសណឹងរៀននៅពេទ្យ១៧ទៀត

ផលៈ ជួបមីងវុធណឹងដែរ

សេងៈ អត់ទេគេនេះភូមិភាគនិរតី ខ្ញុំនៅបស្ចឹម នៅបស្ចឹមណឹងវេទនាណាស់គេហៅមក១៨នាក់គិត ទៅ ស្រាប់តែយប់ឡើងគេមកចាប់គ្រឹបៗអស់អាលីងគេប្រជុំតុមលគេណឹង ដល់ហើយគេ បើលភ្លើង គេចាប់១៦នាក់នៅសល់ខ្ញុំហើយនិងបូរ៉ាត់ដដែល ថាភ័យគ្មានព្រលឹងចុងសក់

ចាប់ចង១ៗគេថារឿងក្បត់ផែនការសម្ងាប់អីៗខ្ញុំក៏អត់មានដឹងនឹងគេដែរ ចុះគិតតែរៀនគិតតែបង្កើនមន្ទីរពេទ្យណឹងដាំដំណាំហូបខ្លួនឯង ស្រុវហូបខ្លួនឯងយប់ឡើងអីចឹង សណ្ដែកដីសណ្ដែកខៀវចុះទៅព្រៃណឹងវាល្អ យើងសុំពូជគេមកដាំ យប់ឡើងសណ្ដែកដី វេនអ្នកណាយាម អ្នកណឹងអ្នកបេះ ប្រឡេះគ្រាប់វាចេញ

ឃីមៈ កាលណឹងមានអ្នកណាប្រធានពេទ្យនៅណឹង

សេងៈ មានតែពូប៉ិន ផ្នែកបច្ចេកទេសហើយពួកខ្ញុំ១៨ ១៩នាក់គេចាប់ទៅអស់ ១៦នាក់ក្រោយមកនៅតែខ្ញុំនិងពីរនាក់បូរ៉ាត់ណឹង ខ្ញុំថានៅមិនកើតទេបូរ៉ាត់ នៅតែពីរនាក់មិនដឹងថ្ងៃណាមួយខ្មែរសគេវៃយើងងាប់ទេនេះ ហើយបានតាស៊ីគណៈភូមិភាគបស្ចិមណឹងគាត់ចុះមកមើលដាក់ស្ដែង គាត់ថាឥឡូវ តាស៊ីណឹងហៅជូដេត ណឹងខ្ញុំនៅផ្ទាល់ ដល់ពេលអញ្ចឹងគាត់ថា ហ្អែងនៅអញ្ចឹងមិនបានទេពីរនាក់បូរ៉ាត់គេវៃចោលងាប់ផុតពូជព្រោះឪខ្ញុំនេះគាត់ខ្មែរក្រហមដែរណឹង ដល់ហើយគាត់យកទៅគាត់នៅជាមួយគាត់ គាត់ថាឥឡូវអញទៅពេទ្យស្រុកចិនពិនិត្យទៅថាគ្រួសក្នុងប្រមាត់ ឥឡូវទៅស្រុកចិនជាមួយអញគាត់ថាអញ្ចឹង ខ្ញុំថាអត់ទៅទេឲ្យបូរ៉ាត់គេប្រុសគេទៅចុះ ឲ្យបូរ៉ាត់គេទៅ គាត់ថាអើចាំដើងក្រោយបើវះចាំហ្អែងទៅឥឡូវគ្រាន់តែទៅពិនិត្យទេ ខ្ញុំក៏អត់ទៅដែរកាលទៅស្រុកចិនណឹងដល់គាត់មកពីស្រុកចិនវិញបានប៉ុន្មានខែ ៥ ៦ខែណឹងក៏ខ្ញុំលែងទៅធ្វើមន្ទីរពេទ្យណាក៏គាត់លែងឲ្យទៅ គាត់ឲ្យនៅមើលគាត់ណឹងហ្មង

ឃីមៈ ឪពុកបងឈ្មោះអី

សេងៈ ឈ្មោះហៀងព្រុំ គាត់នៅពេទ្យ២២ គាត់សេដ្ឋកិច្ច

ឃីមៈ ពេទ្យ២២ណឹងថា ដួន ជឿននៅណឹងមែនទេ

សេងៈ ចា៎ ហើយឪខ្ញុំគាត់នៅពេទ្យ២២

ឃីមៈ ចុះគាត់អ្នកបដិវត្តន៍តាំងពីឆ្នាំណា

សេងៈ មិនដឹងឆ្នាណាទេ ខ្ញុំអត់ដឹងដែរ គាត់អត់ចេះអក្សរអីទេ

ឃីមៈ ចាំសួរគាត់ គាត់ស្គាល់ច្រើន

ឃីមៈ ចុះម៉េចទៀតបង គេឲ្យទៅរៀនពេទ្យអត់ទៅ

សេង៖ គាត់លែងឲ្យទៅគ្រោះនៅក្នុងប្រមាត់ ខ្ញុំនៅមើលថែគាត់ដល់ពេលបើកវគ្គម្តងៗ គេបើកសាលាណឹងទៅប្រចាំការចាក់ថ្នាំទៅព្យាបាលសិក្ខាកាមដូចជាគណៈតំបន់គណៈភាគអីគេគណៈកងពលទៅជាមួយគេណឹងទៅដល់ពេលឆ្នាំ៧៧គេរៀនបកប្រែទូរលេខ រៀនស្រួលទេវពិបាកតែវៃ សុទ្ធតែលេខទាំងអស់ លេខ៦ខ្ទង់ជាសញ្ញាសំងាត់ រៀនមុនដំបូងដូចថាអក្សរកលេខ ៩ អក្សរខ ខេលដប់តាមសពោសំងាត់យើង រៀនណឹងគេអត់ឲ្យមាន ដូចថាខ្ញុំទៅបកណឹង គេអត់ឲ្យស្គាល់ប្អូនឯងធំលើណឹងទេ គេយកផ្ញើឯកសារណឹងមកបើយើងបករួចអាណឹងគេឲ្យរៀន អាណឹងក៏រៀននៅភ្នំពេញដែរ ប៉ុនអត់ឲ្យស្គាល់គ្នា រៀននៅម៨៧០គេក្បែរមាត់ទន្លេ

យឹម៖ ណឹងកន្លែងប៉ុល ពត?

សេង៖ ចា៎ ប៉ុនគេអត់ឲ្យស្គាល់គ្នាទេ គេគ្រាន់តែបកទេ

យឹម៖ ក្បែរមាត់ទន្លេកន្លែងណា ម៨៧០ណឹង?

សេង៖ កាលណឹងខ្ញុំមិនមានសួរដឹងដែរ ចុះគេដឹកចូលតែយប់ ដឹងតែក្បែរមាត់ទន្លេ

យឹម៖ ជិតវត្តភ្នំអត់?

សេង៖ អត់ទេ មិនដឹងកន្លែងណា បើទៅដល់អញ្ចឹងបន្ទប់មួយគេឲ្យយើងចូលផ្ទះថ្ម ហើយមានចេញទៅណាបាយគេយកមកឲ្យហូប មានតែម្នាក់ឯងកំសត់ណាស់ ខ្លាចអីគ្រាន់តែបន្ទប់ផ្សេងៗ

យឹម៖ ចុះគ្រូអ្នកបង្រៀនណឹងអ្នកណាគេ?

សេង៖ អត់មានដឹងឈ្មោះទេ គេផ្ញើឯកសារមកហ្នឹង

យឹម៖ ឯកសារនិយាយពីអី?

សេង៖ និយាយដូចថា ឥឡូវសួរថា មិត្តឯងឈ្មោះអីនៅកន្លែងណា អាយុប៉ុន្មាន បងប្អូនប៉ុន្មាននាក់ គេធ្វើដូចជាប្រវត្តិរូបយើងអញ្ចឹង ដល់ពេលអញ្ចឹងយើងគ្រាន់តែបកអាណឹងដឹងថាគេសួរយើងអញ្ចឹងយើងឆ្លើយទៅគេវិញរួច អាណឹងយើងផ្ញើឯកសារជាលេខណឹងទៅឲ្យគេវិញ គេក៏ឲ្យយើងរៀនបន្តទៀតចេះតែរៀនៗទៅទាល់តែ យឺ ឯកសាគេណឹងច្រើនណាស់

យឹម៖ ចុះគេគ្រាន់លេខសំងាត់រហូត យើងអត់ដឹងន័យទេ?

សេង៖ ន័យអីយើងបកប្រែរួចខ្លួនយើង

ឃីម៖ ចុះន័យស្អីខ្លះ តាមមើល?

សេង៖ ន័យគេសុំ ដូចថាសុំប្រេង ឬមួយគេចាប់មីអូនឯងអញ្ចឹង ឈ្មោះក ឈ្មោះខ ក្នុងឈ្មោះម្នាក់គេសរសេរលេខណឹង៤ដង វង់ក្របកចុះឡើងៗ

ឃីម៖ ចុះហេតុអីបានសរសេរ?

សេង៖ ខ្លាចយើងចាប់ច្រឡំ ដូចថាឈ្មោះសនអញ្ចឹងយើង ចាប់ឈ្មោះសុនទៅមិនត្រូវរឿង

ឃីម៖ ចុះបងមានចាំឈ្មោះអ្នកនាខ្លះដែលត្រូវគេចាប់ណឹងទេ?

សេង៖ គេចាប់ច្រើនណាស់

ឃីម៖ ចាប់ណឹងសុទ្ធតែអ្នកធ្វើអី?

សេង៖ ចាប់ណឹងពួស្នួន អាណឹងគាត់ខាងពាណិជកម្ម

ឃីម៖ ដ័យ ស្នួនណឹង ?

សេង៖ ចាំ នៅកំពង់ស្ពឺ គេចាប់ ខ្ញុំថាអាណិតពួស្នួនដល់ហើយ កាលណឹងគាត់ថាគាត់អត់ស្រួលខ្លួន គេថា ទៅហៅពេទ្យសេងមកគេថាអញ្ចឹង ដល់ហើយអាម្នាក់ចេញទៅហៅខ្ញុំ ខ្ញុំគ្រាន់តែមកកាន់អាបព្រីតុងស្តុង យកមកបំរុងវ៉ាស់ ស្រាប់តែគ្រាន់ខ្ញុំចូលដល់មាត់ទ្វារគេថាលើកដៃលើកដៃចាប់គាត់ណឹង បញ្ជូន ប៉ុនគាត់និយាយច្រើនណាស់ គាត់ថាគាត់បំរើបក្សតាំងពីឆ្នាំ៦១ពី៦១មកឥឡូវមកដល់ បំរើអស់ចិត្តហើយឥឡូវបើបក្សមិនទុកចិត្តខ្ញុំទេ គាត់អស់ចិត្តហើយ គេចង ស្រាប់គេចងមុខ ខ្ញុំថាពូស្នួន ខ្ញុំស្រក់ទឹកភ្នែកប៉ុនលួចស្រក់ គេចាប់ដាក់ឡានអញ្ចឹងឡាន ឡង់រ៉ូវែរសេករហូត

ឃីម៖ ចុះអ្នកណាគេអ្នកចាប់ណឹង?

សេង៖ ទ័ព យប់

ឃីម៖ ស្រែកថាម៉េច?

សេង៖ គាត់ថាអញ្ចឹង ថាបានបំរើបក្សអស់ជាង១០ឆ្នាំចូល២០ឆ្នាំ អស់ចិត្តឥឡូវបើបក្សមិនទុកចិត្តចាប់អញ្ចឹង គាត់ថាបក្សៗអញ្ចឹងគាត់ស្រែកដល់កន្លែងណឹងព្រៃសណឹង

ឃីម៖ ឆ្នាំណាបង?

សេង៖ កាលណឹងឆ្នាំ ៧៦ ៧៧ គេយកមកគុកព្រៃសណឹង ព្រៃសភ្នំពេញណឹង ទួលស្លែងណឹង

យឹម៖ ព្រៃសមានមួយទៀត មានគុកទួលស្លែង

សេង៖ គុកព្រៃសណឹង ប៉ិនយប់គេយកមកម៉ោង៩យប់ គាត់ស្រែកចង់មុខចង់ដៃ គាត់ដល់ថាដល់កន្លែងនេះៗគាត់នៅតែថាអញ្ចឹង

យឹម៖ ចុះបងមកជាមួយគាត់រហូត?

សេង៖ មកមួយរហូត

យឹម៖ ចុះថីបានមកជាមួយគាត់?

សេង៖ ចុះកាលណឹងបើកាលណាយើងរត្ថន់ទៅជាមួយគ្នាអញ្ចឹងចាប់មួយកាលណាយើងចេញក្រៅបែកការណ៍ គេថាខ្មាំងណឹងម៉េចដល់កន្លែងទិសដៅ ឧទាហរណ៍ថាបែកការណ៍ចេញក្រៅ គេមកចាប់យើងទៀតហើយ គេឲ្យទៅដើម្បីបំបិទភស្តុតាងកុំឲ្យអ្នកនៅមន្ទីរណឹងដឹងថាចាប់អ្នកនេះអ្នកនោះ កុំឲ្យយើងនិយាយ គេសំងាត់មាំណាស់

យឹម៖ ចាប់អ្នកណាទៀត?

សេង៖ ចាប់ពូទូច ពូទូចណឹងផ្ទះនៅកំពង់ចាម

យឹម៖ តូច ភឿនមែន?

សេង៖ មិនដឹងឈ្មោះអីផង កាលណឹងគាត់ប្រធានរោងចក្រដំបាញ

យឹម៖ អូ មិនមែនទេ

សេង៖ ដែលស្គាល់ទេ នៅគុកព្រៃស ច្រើនណាស់នៅភូមិភាគបស្ចឹមថាហូរហែរខ្សែហគណៈតំបន់

យឹម៖ ពេលគេចាប់គេហៅបងទៅដើម្បីបន្ទំភ្នែក?

សេង៖ អត់ទេ បន្ទំដូចថាពេលកាលចាប់ពូទូចគាត់ឈឺ គេហៅអញ្ចឹងថាឲ្យខ្ញុំ និងពូមួយទៀតនៅព្រែកក្តាមខាងទ័ពក៏គេចាប់

យឹម៖ ចុះស្គាល់ទីវអុលទេ?

សេង៖ អត់

យឹម៖ ចុះពេលបងរៀនសំងាត់ណឹងគេរៀនអីខ្លះ ទូរលេខសំងាត់គេណឹង?

សេង៖ គេរៀនតែលេខ បកប្រែ និងចាប់មនុស្ស និងរៀនផ្តល់របស់ ដូចថារបស់ធំៗត្រាក់ទ័រ ប្រេង ម៉ាស៊ីនប្រេង មកពីកន្លែងមជ្ឈិមគេ ផ្ញើទៅភូមិភាគ ដូចថាពត៌មានព្រឹត្តិការអីផ្សេងៗដូចថាពត៌មានថាផ្លូវត្រូវមានកន្លែងណាមានគិញមានខ្មាំងអីគេ ទៅតាមដានតែក្នុងរៀនណឹងពិបាកដែរ ៥០ម៉ែត្របួនជ្រុងអត់មានទៅណាបានទេ អត់ស្គាល់គ្នាទេ គេអ្នកយកបាយឲ្យយើងគ្រាន់តែយកបាយឲ្យយើង យើងអង្គុយតែសរសេរណឹងនិងរៃអង្គីលេខ

ឃីម៖ អូអាណឹងបងចេះហើយ ចុះកាលពីដំបូងបងអត់ទាន់ចេះអ្នកណាគេបង្រៀន?

សេង៖ ដំបូងអត់មានទេ គ្រាន់តែគេយកក្រដាសខ្ញុំចេះតែរៀនទៅ រៀនបក តាស៊ីណឹងគាត់ថា អញ្ចឹងហ្អែងនៅជាមួយអញ នៅជាមួយគាត់រហូតទៅ ពេទ្យផងបកប្រែទូរលេខផង

ឃីម៖ ចុះមករៀននៅភ្នំពេញប៉ុន្មានខែ នៅកន្លែងម៨៧០បានត្រឡប់ទៅកន្លែងតាស៊ីវិញ?

សេង៖ អត់ទេ មករៀនតែកន្លះខែ ចុះអត់មានបានសំរាកទេយប់ ក្នុងម៉ាយប់សំរាកខ្លាំងណាស់ បានកន្លះម៉ោង ពិបាកមែនទែន ផ្ទះអីអត់ដែលមកទេ មិនដែលស្គាល់ផ្ទះម៉ែឪនៅណាអី អត់ដឹង

ឃីម៖ តាមស្មានមើល មាននារីប៉ុន្មាននាក់ទៅជាមួយបង?

សេង៖ នារីតែខ្ញុំនិងនៅកោះកុងមួយ ក្រៅពីណឹងសុទ្ធតែយុទ្ធជនទាំងអស់

ឃីម៖ ចុះមានដែលឃើញប៉ុលពតទេពេលនៅ៨៧០ណឹង?

សេង៖ ឃើញដែរ

ឃីម៖ គាត់ទៅធ្វើអី ?

សេង៖ ប៉ុល ពតបើកវគ្គៗប្រចាំការសាលាខ្ញុំ

ឃីម៖ វគ្គនយោបាយនោសាលាណា?

សេង៖ ផ្សារកំពង់ឆ្នាំលើ

ឃីម៖ ចុះម៉េចទៅនៅកំពង់ឆ្នាំលើវិញ?

សេង៖ ចុះគេបើកវគ្គ គេមិនទៀត

ឃីម៖ ក្រែងផ្ទះគាត់នៅភ្នំពេញ?

សេង៖ ផ្ទះនៅភ្នំពេញ ប៉ុនគេចុះតាមភូមិភាគ

យឹមៈ មានដឹងថានៅម្ដុំណាទេ ផ្ទះនៅភ្នំពេញ?

សេងៈ អត់ដឹង ប៉ុលពតណឹងស្គាល់តែមុខគាត់ នៅពេលគាត់ទៅ ពេលគាត់ឈឺគាត់ហៅខ្ញុំមកពិនិត្យ ជួនកាលអត់ឈឺ ហីខ្ញុំចេះថា ហីគាត់ចេះថា បានយកបាញ់ចោល

យឹមៈ គាត់ឈឺម៉េច?

សេងៈ គាត់ឈឺដូចថា ចុះគាត់អ្នកធំ ពេទ្យ ៥ ៦នាក់ ដូចថា៥នាក់ ពិនិត្យទៅគេជ្រើសរើសពេទ្យណាៗ ដល់ពេទ្យមួយគេឲ្យវ៉ាស់ឈាម គេអត់ឲ្យមាត់ទេ ហើយមួយទៀតគ្រប់៦នាក់ បើឆ្លើតគេឲ្យឆ្លើយត្រូវគ្នា ឆ្លើយដំណាលគ្នាអ្នកណាថាម៉េចៗ

យឹមៈ ណឹងប៉ុល ពតឲ្យធ្វើ

សេងៈ ចា៎ ដល់ហើយយើងឆ្លើយដូចថាជីពចរមានប៉ុន្មាន ថាប៉ុណ្ណឹងគេ ឲ្យត្រូវគ្នា ឲ្យស្រុះគ្នាអត់មានម្ដងម្នាក់ទេ

យឹមៈ ចុះបើថាខុសគ្នាម៉េច?

សេងៈ បើខុសគ្នាគេថាពេទ្យណឹងរៀនម្ដងទៀត ពិនិត្យម្ដងទៀតគេឲ្យវ៉ាស់សារថ្មីម្ដងទៀត

យឹមៈ ចុះ៦នាក់ណឹងមានអ្នកណាខ្លះចាំឈ្មោះ?

សេងៈ មកពីមជ្ឈមណឹងមិនដឹងប៉ុន្មាននាក់ ពួកខ្ញុំ មានតែខ្ញុំមួយទេនោភូមិភាគណឹង ចុះព្រោះអីនៅផ្ទាល់ជាមួយតាស៊ីហើយ

យឹមៈ ឆ្នាំណាកាលពិនិត្យណឹង ?

សេងៈ ពិនិត្យណឹង ៧៧ហើយ

យឹមៈ ចុះគាត់ចេះតែឈឺម៉េច?

សេងៈ គាត់ដូចថាហត់ ខ្ទេសនាមឯកសារយូរ ចេះហត់ឡាហ៊ីឡាហៃអីណឹង ហើយខ្ញុំចេះតែថាដែរ តែយើងមិនដែលបញ្ចេញពលកម្មដល់និយាយបន្តិបន្តួចរួយមាត់រួយថ្គាមហើយមានអីធម្មតា

យឹមៈ ចុះប៉ុលពតថាម៉េច?

សេងៈ មានថាអី គាត់ថាបានបាញ់ចោលពេទ្យណឹងមកពីណាអីក្លាហានមាំម៉េស ខ្ញុំថាមើលអី បើជីពចរធម្មតាឈាមធម្មតា បេះដូងធម្មតា ហើយថាឈឺអីចុះ កាលនោះអត់ចេះខ្លាចទេ

ឃីមៈ  កាលនោះនៅក្មេងប្រហែលអាយុប៉ុន្មាន?

សេង៖  ១៨ ១៩ ឆ្នាំ

ឃីមៈ  ហើយប៉ុល ពត អត់ប្រកាន់ទេ?

សេងៈ  អត់ទេ បានតាស៊ី គណៈភូមិភាគគាត់វង គាត់ថាក្មួយគាត់ គេថាភូមិណឹងភូមិសង្គមនិយម

ឃីមៈ  ចុះប៉ុល ពតទៅខ្មែរទាមៗពីអីខ្លះ ?

សេងៈ  កាលណឹងទៅកំពង់ឆ្នាំង មានបានចូលសាលគេណា យើងពេទ្យគ្រាន់នៅកន្លែងចានកន្លែងឆ្នាំង ដល់ពេលអ្នកណាឈឺបានគេហៅទៅបើថាអត់ទេដាំតែបាយស្ល

ឃីមៈ  ចុហប៉ុ ពតស្អាតទេ?

សេងៈ  ធាត់កន្ទុលៗ ធំដែរណឹង

ឃីមៈ  ចុះបងរៀនចប់មកកន្លែងតាស៊ីវិញនៅណា ពេលរៀនចប់ពីទូរលេខសំងាត់ណឹងហើយ?

សេងៈ  នៅច្បារមន ខេត្តកំពង់ស្ពឺនៅកន្លែងចំការដូងបន្ទាយគេ ឲ្យខ្ញុំនៅណឹងបង្រៀនក្មេងតូចៗអីអា១៧ទៅរៀនអក្សរ ខ្លះរៀនវៃអង្គីលេខ ខ្លះរៀនចូលទៅរោងពុម្ពវិញ

ឃីមៈ  ទៅអញ្ចឹងវិញរៀនពេទ្យសុខៗ

សេងៈ  ចុះនៅគ្រាន់ព្យាបាលតាស៊ីនិង តាប៉ាល់គណៈភូមិភាគណឹង

ឃីមៈ  ចុះតាស៊ីអនុ?

សេងៈ  តាស៊ីប្រធាន តាប៉ាល់អនុ ពូរ៉ែនសមាជិក ផ្ទះគាត់នៅកោះកុង

ឃីមៈ  តាស៊ីណឹងប្រពន្ធកូនអីនៅណឹងដែរ?

សេងៈ  តាស៊ីអត់មានកូនទេ មានប្រពន្ធ ប្រពន្ធគាត់គណៈស្រុកខដុក្គ តាប៉ាល់ប្រពន្ធគាត់ចាស់ អត់មានធ្វើអីផងនៅតែមន្ទីរ

ឃីមៈ  ចុះកន្លែងណឹងគេឲ្យបងធ្វើអីខ្លះ?

សេងៈ  កន្លែងណឹងនៅ តាប៉ាល់គាត់បួសថ្មើម តាស៊ីណឹងកាត់ប្រម៉ាត់ តាស៊ីមុនខ្ញុំទៅនៅជាមួយគាត់តាំងពីមុនគាត់កាត់ប្រម៉ាត់ ដល់វះទៅកាត់ប្រម៉ាត់ គាត់ឲ្យនៅជាប់ជាមួយគាត់ដល់ពេលទៅវះណឹង ខ្ញុំទៅជាមួយគាត់ដែរណឹងចូលកន្លែង១៧ណឹងតែគ្រាន់យើងអត់មានកាន់

អីទេ គ្រាន់តែឈរមើលដាក់ស្ពែងក្រែងលោមានអ្នកណាបន្ទំដាក់ថ្នាំ ឬវះឲ្យវាត្រូវឆូតត្រូវពោះវៀន នោមើលរហូត

យឹម: កាលនឹងអ្នកណាគេអ្នកវះ?

សេង: វះណឹងតាដួន ជឿនណឹង និងចិនបីនាក ហីប្រើសុទ្ធតែម៉ាស៊ីនទាំងអស់ ជំនាន់ណឹងគេប្រើម៉ាស៊ីនឃាត់ឈាមហើយដាក់ទៅបាច់ៗមិនបាច់គ្នាច្រើនទេ ទំនើបដែរណឹង

យឹម: ចុះបងមានដែលរៀនជាមួយដួន ជឿនទេ?

សេង: រៀនវគ្គ ៥ខែ វគ្គឯកទេសអីណឹង

យឹម: ចុះគាត់មាននាទីអីគេ?

សេង: គាត់ខាងវះកាត់គាត់អត់ចេះចាក់ថ្នាំអីទេ វះកាត់ម៉ាមុខ ដុចថាខ្ញុំបញ្ជូនអ្នកជំងឺ ធំៗទៅពេទ្យឲ្យខ្ញុំអ្នកវាស់ឈាម ផ្នកចាក់ថ្នាំ គាត់ចេះកាន់តែម្ជុលនិងកាំបិត

យឹម: ចុះគាត់មាននិយាយអីម៉េចទេ?

សេង: អត់មាននិយាយអី ពេលដូចថារៀនយើងរៀន គាត់បង្រៀនខាងឯកទេសវះកាត់ គាត់និយាយពីរឿងវះកាត់ដូចថាជំងឺអីដែលយើងត្រូវវះរបួសណាដេលយើងព្យាបាលមិនបានមាន កំទេចឆ្អឹងយើងត្រូវវះកាត់ណឹងគាត់ពន្យល់ងារឿងណឹងទៅ ដល់រៀនវគ្គទូទៅ៧៥ហូបតែនំប៉័ង ហូបជាមួយសម្ភត្រកួន តឹងតែងចុះមានអីហូបអត់ ហូបតែសម្ភត្រកួននិងនំប៉័ងនិងសម្ភត្រកួនម៉ាឆ្នាំមកគ្នា ១០នាក់ ហូបអត់ឆ្អែតទេ ពេលឡើងទៅរៀនណឹងសណ្ឋាគារ ផ្ទះថ្មគេណឹងបួនជាន់ ទីបួនមុនដំបូងមានអី នាំគ្នាស្លៀកសំពតទៅរៀនបាន ដល់បានពីរខែសុទ្ធតែខោហើយ ស្លៀកលេងជាប់វាស្គម ចុះមានអីហូប កំសត់កេរត់ចេញអស់នៅតែខ្ញុំខ្ញុំថារត់មកផ្ទះក៏មិនផាយ

យឹម: ម៉ាវគ្គណឹងប្រហែលប៉ុន្មាននាក់?

សេង: មានពីរពាន់ប្រាំរយ មកពីគ្រប់ភូមិភាកទាំងអស់

យឹម: ៧៥ភ្លាមគេធ្វើភ្លាម?

សេង: ចាំ ៧៥ ភ្លាមនិងគេរើសពេទ្យមធ្យម ទៅទាំងអស់ដចថាម៉ាមន្ទីរតំបន់មានពេទ្យមធ្យមប៉ុន្មានគេរើសបីបួននាក់គ្រប់ភូមិភាគគ្រប់តំបន់មក ខ្លះពេទ្យស្រុកអីទៅអញ្ចឹង

ឃីមៈ ចុះដាងពីរពាន់នាក់ដេកត្រង់ណាខ្លះ?

សេងៈ ដេកនៅកន្លែងបន្ទាយស៊ីក ៧៥ណឹង

ឃីមៈ ច្បាស់ហើយ៧៥ណឹង

សេងៈ ចា៎

ឃីមៈ បងមួយនោះទៅរៀន៧៧

សេងៈ អាណឹងវគ្គទី២ ខ្ញុំវគ្គដំបូងគេបង្អស់ វគ្គនំប៉័ង រត់ចង់អស់

ឃីមៈ ពីរពាន់នាក់នៅសល់ប៉ុន្មានរត់ទៅ?

សេងៈ រត់ទៅដូចនៅសល់បងសីគាត់ រឿងបងសី ខ្លះគេមានខ្នងគេរត់បាត់ទៅ

ឃីមៈ អញ្ចឹងគេដឹងបងសីណឹងក្បត់តាំងពី៧៥?

សេងៈ ចា៎ គេដឹង

ឃីមៈ ចុះប្តីបងសីណឹងឈ្មោះអី?

សេងៈ មិនដឹងឈ្មោះអី កាលនោះគ្មានអ្នកណាហ៊ានប្រវត្តិអ្នកណា

ឃីមៈ ក្រៅពីបងសីមានស្គាល់ពីណាទៀតនៅក្នុងពេទ្យណឹង ចុះពេទ្យធ្មេញឈ្មោះអី?

សេងៈ មិនដឹងពេទ្យឈ្មោះអីផង កាលណឹងពេទ្យ១៧ណឹងដូចពិបាកដែរ ពិបាករឿងរស់នៅជីវភាព គេធ្វើបាបសិក្សាកាមដែលទៅរៀនណឹងមិនចង់ឲ្យបេះទេ

ឃីមៈ ហេតុអី?

សេងៈ មិនដឹង ហេតុអី បើយើងអ្នកណាយកចិត្តទុកដាក់ទៅដូចថាស៊ុះស៊ុាយកអ្នកជំងឺមកប្តូមួយក៏ ប៉ុនសួរប៉ុនឆ្ងល់ទៅអាណឹងបានជាគេបកស្រាយប្រាប់បើមិនអញ្ចឹងទេគេយកឯកសារដុំៗយ កមកឲ្យយើងមើលហ្នឹង រៀនទ្រឹស្តីដល់ហើយ ដល់ហើយឧទាហរណ៍អ្នកជំងឺថ្មីចូលមកគេ អ្នកទៅរៀនថ្មីទៅពិនិត្យវិនិច្ឆ័យថាជំងឺអីម៉ា"ក្រុមគេបែកគ្នា១០នាក់ពិភាក្សាគ្នាទៅដូចជំងឺរបេ ង យើងយកគំហាកនិងទៅឲ្យគេពិនិត្យទៅ បើថាគ្រុនចាញ់ជួសឈាមឲ្យគេពិនិត្យទៅបើ យើងវិនិច្ឆ័យថាបាន២ថ្ងៃបានគេឲ្យលទ្ធផលមកបើយើងត្រីវទើបយើងដឹងថាជំងឺត្រូវហើយ បើអត់ត្រូវអត់មានក្រុមគេផ្សេងដែលគេវិនិច្ឆ័យត្រូវរបស់គេ ដល់ហើយគេឲ្យលទ្ធផលតាម

ឃីមៈ ចុះក្នុងពេទ្យ១៧មេសាកាលណឹង បងដឹងថាមានផ្នែកអីខ្លះទេ រៀន៥ខែអាចចាំដែរ

សេង: ចាំដែរតែមិនដឹងមានផ្នែកអីខ្លះទេ ចុះមានដែលទៅមាត់រកគ្នាណាបើម៉ោង៧ចូលរៀន ទ្រីសី ហឺភូមិភាគបស្ចឹមខ្ញុំណឹងទៅតែបីនាក់ខ្ញុំនិងបងការម្នាក់ទៀតនៅផ្សារកំពង់ឆ្នាំខ្ញុំដឹងតែវះ កាត់តូចវះកាត់ធំ

ឃីម: ចុះស្គាល់ប្រធាន ផ្នែកនមួយៗទេ?

សេង: មិន ភ្លេចអស់ហើយកាលមុនស្គាល់ទាំងអស់ណឹង តែឥឡូវវាភ្លេចអស់ទៅ ប៉ជាង២០ឆ្នាំ

ឃីម: ត្រូវហើយ បើបងអត់និយាយកប់បាត់ ចេះខ្ញុំមកសួរដឹងរឿងច្រើន

សេង: ខ្ញុំតែឪពុកមតាយឪ ណឹងក៏ឪ មិនដែលនិយាយប្រាប់ថាប្រវត្តិដូរចត់ អត់ដឹងគេវែងស្មេ កូនទំរាំបានប៉ុណ្ណឹង ហឺពេទណឹងក៏អញ្ចឹងដែរកេអត់ដឹងខ្ញុំរៀនពេទ្យបានជ្រៅជ្រះព្រោះអីខ្ញុំទៅតាំងពីអាយុ១៦ឆ្នាំទៅរហូតដល់ចេះខឹងកេដៀលថាអញ្ចឹងថាកូនអ្នកមានទៅណាដែលរួច ហឺនៅជាមួយបញ្ញវ័ន្តទៀតវាចេះអីវាទៅស៊ិក្តាមស៊ិខ្យងបានគេថាអញ្ចឹង ខ្ញុំរៀនថ្នាក់ទី៦ ចាស់

ឃីម: ចុះពេទ្យឆ្មេញមានស្គាល់ឈ្មោះឌីផុនទេ នោក្នុងពេទរុស្សីណឹង?

សេង: ដូចដែលឮដែរ

ឃីម: ឌី ផុនគេហៅធុក

សេង: អូ ណឹងហើយ តាធុកចឹមិនស្គាល់

ឃីម: ហឺ ចុះអត្តចារកគាត់?

សេង: គាត់មានអី គាត់អ្នកបង្រៀនទាំងអស់សុទ្ធតែស្រួលដែរ មានពិបាកអី ខូចតែគ្នាឯងដូចថាពេទ្យភាកអីដូចគ្នាអាធំៗដូចគ្នាណឹងគេប្រណែនគ្នាប្រណាំងគ្នាដូចកូនសិស្សឥឡូវយក លេខមួយលេខពីរប្រណាំគ្នាពីក្រុមមួយទៅក្រុមមួយខ្ញុំកាលណឹងមិនអីចុះអ្នករៀនណឹងសុទ្ធតែអ្នកចេះច្រើនៗសុទ្ធតែអនុធនសិស្សវគ្គដំបូងត្រឹមថ្នាក់ទី៧ ទី៦ អាខ្លះទី៣ទៅរៀន ណឹងកាលណាខ្ញុំតូចជាងគេដែរប៉ុនអត់ចេះ ខ្លាចតាំងចិត្តអញ្ចឹងគេអត់ប្រលងទេជាក់ស្តែងនៅ កន្លែងមន្ទីរគេរើសយកទៅដូចថាខ្ញុំធ្លាប់ទៅនោពេទ្យដីឆ្នាំ និងនៅពេទ្យចំពុះវ័ន្ត

ឃីម: ដូរច្រើនពេទ្យម៉េស?

សេង៖ ចុះរៀនមុនដំបូង គេឲ្យនៅពេទ្យតំបន់ ហើយគេបញ្ជូនទៅពេទ្យកងពលគេពិសោធន៍ឲ្យយើងរៀន កងពលហើយបានទៅណឹង សុទ្ធតែក្នុងភូមិភាគបស្ចឹម ចំពុះវិទ្ធណឹងគឹកងពលទី១ កាល៧៥ណឹង មកពីពេទ្យចំពុះវិទ្ធវិញបានមករៀនណឹង

យឹម៖ បងនេះប៉ុលពតនេះ ទស្សនាវដ្ដីចេញខែណឹង នេះមុខគាត់មែន មុខអញ្ចឹងមែនទេ

សេង៖ ណឹងហើយ ប្រើតែក្រមាក្អុកទេ ហើយខោចែវ

យឹម៖ អូ ដូចប្រធានខ្ញុំដែរ គាត់ចូលចិត្តខោចែវដែរ

សេង៖ ចា៎ ខោចែវនិងអាវចិន

យឹម៖ ចុះសំដីគាត់ម៉េចដែរ ពិរោះស្លូតបូត ឬក៏ ចេញមកឃោរឃៅ?

សេង៖ ជាមួយប្រជាជនកេចេហតែស្លូតហើយ ជាមួយ ប៉ុនខ្ញុំមិនដែលទៅរៀនផ្នែកនយោបាយជាមួយគេដែរ

យឹម៖ ចុះគាត់និយាយជាមួយបងឯងម៉េចដែរ?

សេង៖ សំដីគាត់សំឡុតហើយសុទ្ធតែបាញ់ចោល សុទ្ធតែកាប់ សុទ្ធតែចាក់ឃោរឃៅ បើថាចូលចង្ក្រានដុកបើថាពាងប្រហុកមានដង្កូវនៅក្នុងក្រឡុប៉ិនណ្ដេះមានសុទ្ធតែបាញ់ចោល ហឺបើទឹកអប់គេអត់ឲ្យប្រើទេតែបើខ្ញុំសាកមើលបន្ទប់ទឹលមួយខ្ញុំអត់ដាក់សាប៊ូក្រហបសួរថា អ្នកណាជាអ្នករៀបចំបន្ទប់ទឹកនេះ ខ្ញុំថាខ្ញុំ ចុះម៉េចអត់មានសាប៊ូក្រអូប ខ្ញុំថាចុះក្រែងបំបាត់ធាតុក្រអូបចុះរកសាប៊ូក្រអូបធ្វើអីគាត់ថា ហ៊ីបានតែបាញ់ចោល តមាត់អញ្ចឹង ខ្ញុំថា បើបាញ់ចោលក៏បាញ់ទៅជីវិតតែមួយមិនមានលក់ផ្សារណា ខ្ញុំអត់ចេះខ្លាចដែរ

យឹម៖ ចុះប៉ុលពតថាម៉េច?

សេង៖ គាត់មានថាអី គាត់ថាអើស ត មាត់វើយ អានេះអត់ចេះខ្លាច

យឹម៖ ចុះគាត់ចំណាស់ម៉ាន

សេង៖ គាត់ចាស់ដែរហើយ

យឹម៖ ចុះប្រពន្ធកូនដែលឃើញទេ?

សេង៖ អត់ដែលឃើញទេ

យឹម៖ កាលបងរៀបន្ទប់ទឹកនៅណា?

សេង៖ នៅកំពង់ឆ្នាំងផ្សារលើ គាត់ចូលមកម៉ាភ្លែតៗគាត់មកបើកវគ្គកន្លះខែ នោះដាំបាយ ខ្ញុំគ្រាន់នៅពិនិត្យអីជាមួយគាត់ ដាំបាយស្ល ខ្ញុំបានតាស៊ីគាត់ស្រឡាញ់ដូចកូន ហីប្រពន្ធគាត់ក៏អញ្ចឹងដែរមកកំសត់បែកគ្នា តាស៊ីគេចាប់គាត់ ការចាប់ណឹងវេទនាណាស់ខ្ញុំវ៉ាន់អត់ថារស់ទេបើខ្សែជាមួយគ្នាហើយយើងនៅផ្ទាល់ចឹងទៀត គេចាប់ កាលណឹងនៅទូរលេខគាត់នៅកោះតាសែននៅជិតព្រមប្រទល់ពាយ័ព្យ ហីខ្ញុំនៅច្បារមនណឹង ដល់ពេលខ្ញុំនៅចឹងទៅគេទូរលេខមកថាឲ្យតាស៊ីណឹងម៉ោង៨ព្រឹកកន្លះមិនថ្ងៃទីប៉ុន្មានព្រោះអីខ្ញុំមិនស្មានថាខ្ញុំរស់ទេទល់ថ្ងៃនេះទោះឪពុកម្ដាយខ្ញុំក៏អត់ដឹងថាខ្ញុំពិបាកអញ្ចឹងដែរ ដល់ហើយគេថាមោ៉ង៨កន្លះជិតភ្លឺ គិតតែទូរលេខម៉ោយប់ណឹងអត់មានបានដេកទេ គេហៅ ឲ្យទៅហៅតាស៊ីណឹងទៅ ប៉ុនមុនណឹងក៏ខ្ញុំដឹងដែរ មុនណឹងប្រហែល៧៨របហែលខែ១ខែ២ គាត់ប្រាប់ខ្ញុំថាឥឡូវហ្អែងយកមាសម៉ាដ្ដិលខាត់ទៅ គាត់ថាអញ្ចឹងខ្ញុំថាយកទៅណាអ៊ំ គាត់ថាយកទៅនៅពតខ្លួនលាក់ខ្លួនធ្វើជាអ្នកឈឺទៅនៅផ្ទះទៅនៅស្រុកកំណើតព្រោះអីនៅ៧៩ណឹងមានបក្សពីរ ហើយបើយើងឈ្នះអត់ចាយលុយអត់ចាយមាសទេ គាត់ថាអញ្ចឹងខ្ញុំថាអត់ទៅទេអ៊ំអាបិតមួយគេមក មុនគេថាអាបិតណឹងចូលគណៈបក្សអីគេណាបាត់ហើយ អាបិតណឹងបងប្អូនតាម៉ុក គេមកគេថាទៅអត់ពេទ្យ ខ្ញុំថាអត់ទៅទេសុខចិត្តស្លាបរស់នៅនេះហើយ គាត់ថាបើសិនណាគាត់ខុសអស់តាស៊ីគាត់ប្រាប់ខ្ញុំអញ្ចឹង ខ្ញុំថាខុសអីអ៊ំ បើសិនឲ្យហ្អែងរៀនធ្វើកញ្ជើរធ្វើឈ្នៀងអីបានប្រើឲ្យហ្អែងរៀនធំៗពេកអត់ ម៉ាជំនាន់ទៀតគេឈប់យកហ្អែងព្រោះអីប្រវត្តិរូបហ្អែងអត់ល្អព្រោះយើងធ្លាប់ធ្វើម៉ាជំនាន់នោះអញ្ចឹងមកជំនាន់នេះឥឡូវគេគាបយើងបន្តិចហ៉ោយ

ឃីម៖ គាត់ចង់និយាយម៉េច ?

សេង៖ ចង់និយាយជំនាន់ឥឡូវនេះមិនដឹងគេធ្វើម៉េចគាត់អត់ដឹងដែរព្រោះអីយើងធ្លាប់ជំនាន់នោះអាញ្ចឹងនៅជាមួយគណៈតំបន់អីគេចេះតែរៀនសូត្រដែរគាត់ថាគេវែងស្មុំទំរាំហ្អែងល្អហ្អែងវេទនាហើយ ពាក់កណ្ដាលអាយុ គាត់និយាយប្រាប់អាញ្ចឹង ហីឲ្យទៅរៀនពេទ្យក៏អត់មានបានប្រយោជន៍ ហើយរៀនទូរលេខវៃអង្គីលេខ បកប្រែនៅរោងពុម្ពចុះទស្សនាវដ្ដីអីណឹង

ឃីម៖ ចុះបងអ្នកចុះទស្សនាវដ្ដីដែរ?

សេង៖ រហូរដែរណឹង គ្រាន់តែអូសអារ៉ូមេអូគេនោះហើយតំរៀបគ្នាទៅ ចុះទស្សនាវដ្ដីរូបភាពដែរ

ឃីម៖ គេនិយាយពីអីទសសនាវដ្ដីគេណឹង?

សេង៖ និយាយពីការបង្កបង្កើនផល កាលណឹងដូចទន់បដិវត្តន ប៉ុនខ្ញុំមិនមែនប្រធានទេ ដូចខ្ញុំទំនេរការងារចឹងទៅគេហៅទៅជំនួយការ ទៅបង្រៀនក្មេងៗអូសគេឲ្យអូសណឹងក៏នេះដែរ ជួនកាលខ្វះអត់អក្សរ អូសបញ្ច្រាសក៏មានដែរ ដល់យើងអ្នកចេះដើរមើលអាណាបញ្ច្រាសដាក់ដំរង់

ឃីម៖ ចុះបានន័យថាទន់បដិវត្តន៍ណឹងសុទ្ធតែចេញមកពីកំណ័ស្តីវិញទេ ?

សេង៖ កំពង់ស្តីអាណឹងតាមភូមិភាគគេបស្ទីមមិនមែនទូទាំងប្រទេសទេ ហឺព្រឹត្តិការណ៍ប្លែកៗយើងយកពីមជ្ឈឹមខ្វះមកយកមកសារុបគ្នាគេធ្វើទសសវដ្តីរូបភាពណឹង ហើយមានគេអ្នកគូកាលនោះមានអីផតដូចឥឡូវទេ មានពូមួយឈ្មោះពូប៉េន ពូប៉ន គាតណឹងដើងឯកទេសគូហើយ តាអ៊ុយមយយទៀត គ្រាន់តែឃើញខ្ញុំអញ្ចឹងឲ្យគាត់គូដូចបេះដាក់ ហឺអក្សរក៏អញ្ចឹងដែរ អក្សរស្អាតជាងគេអក្សរពូប៉ន គាត់សរសេរហើយម៉ាសន្លឹកអញ្ចឹងហើយយើងយកទៅអូស២រយបីរយសន្លឹកទៀតទៅ អត់មានបានវៃដាក់ទីលូទេអក្សរគាត់ជ្រុងៗ អាមួយមូលអក្សរពូប៉េនផ្ទះគាត់នៅ១០៦ឥឡូវមិនដឹងម៉េចទេបែកគ្នាអស់ត្រឹមគេចាប់តាណឹង ។ពេលគេចាប់តាស៊ុណឹង គេទូរលេខមកថាក្មេងពីអាយុ ៦ឆ្នាំឡើងទៅយកទៅទាំងអស់

ឃីម៖ អូ សាហាវ អ្នកណាគេអ្នកស៊ីញ៉ូ?

សេង៖ មិនដឹងអ្នកណាគេស៊ីញ៉ូ គេអត់មានស៊ីញ៉ូទេកាលនោះ គ្រាន់តែគេបោះត្រាមកកាលនោះអត់មានស៊ីញ៉ូទេដឹងថាអាណាអត់ ឲ្យយើង

ផល៖ ក្មេងពីអាយុ៦ឆ្នាំណឹង?

សេង៖ អ្នកនៅជាមួយខ្ញុំ នៅជាមួយតាស៊ីណឹងនៅមន្ទីរ៤០១ណឹង

ឃីម៖ ចុះមន្ទីរ៤០១ណឹងសំរាប់អី?

សេង៖ មន្ទីរ៤០១ណឹងសំរាប់កន្លែងភូមិភាគណឹងហ្នឹងគេយកទៅអស់អាលីង៦ឆ្នាំ ប៉ុនមុនមកយកតាម៉ុកចូលមក តាម៉ុកណឹងមកដល់គាត់សួរថា មើលអាសេងទៅណាហើយ គាត់ថាអញ្ចឹងគាត់ដឹងខ្ញុំនៅណឹងគាត់ស្គាល់កាលណឹងគាត់ធ្លាប់តស៊ូជាមួយឪខ្ញុំនេះ ដល់ហើយខ្ញុំចេញមកដល់ចេញមកគាត់ថា មើលមានថ្នាំបំពុលប៉ុន្មានទៀតទុកបំពុលអញ គាត់ថាអញ្ចឹង ខ្ញុំថាឥឡូវអ៊ឹងឯងផែកឃើញមានថ្នាំពុលយកខ្ញុំទៅបាញ់ចោលទៅមានជីវិតពីរជីវិតបីមានកូនមានចៅណាឲ្យជាប់វាក់វិន់ អេិបើអញ្ចឹងបានជាហ្អែងអត់យកប្តីគាត់ថាអញ្ចឹង ខ្ញុំថាយកអីបើខំ

គស៊ូចង់ងាប់ តាំងពីស៊ីអត់អំបិលខ្ញុំថាឲ្យតាម៉ុកចឹង តាំងស៊ីដេះស្ទីត រហូតឥឡូវមានអំបិលហូបហើយដល់ពេលមានប្ដីយកទៅតាមបាត់មានធ្វើការអីសោះអួសតែសាក់កាដូរតាមគេខ្ញុំមិនយកទេ ហើយតាម៉ុកគាត់ថា អញ្ចឹងទុកធ្វើប្រពន្ធចុងតាស៊ី ខ្ញុំថាប្រពន្ធចុងឥឡូវចាំសួរយាយលីទៅ ចង់ចោទ យាយលីគាត់មកសំរានណឹង យាយលីប្រពន្ធតាស៊ីណឹងគាត់មកសំរានរាល់តែយប់ បើតាស៊ីគាត់អត់ប្រមាត់ហើយយាយលីណឹងគាត់រលៀកស្បូនពេលមាខែអីចឹងគាត់មកស្ងាំងមាំដង កាត់មកសំរាន់ណឹងរាល់តែយប់ ខ្ញុំថាទៅសួរយាយលី ហើយសួរមិត្តនារី មិត្តយុទ្ធជនទាំងអស់ណឹងប្អូននេះណឹងមួយដែរ ពូហនណឹងប្រធានមន្ទីរ៨០១ណឹង គាត់ថា ហ៊ីឥឡូវវាចេះតថ្ងៃច្រើនណាស់នៅជាមួយអាក្បត់យួរ នៅជាមួយយួនយួរចឹងហ្នង តាម៉ុកថាឲ្យខ្ញុំអញ្ចឹង ដល់ហើយគាត់ថា ណាកន្លែងដេក ខ្ញុំថា កាលណោះមានគ្រែមានអីត្រឹមត្រូវចុះកន្លែងភូមិភាគមានខ្នើយមានពូកអី អញមិនមិនដេកទេ វរៗដាក់ម៉ុនងាប់អញ គាត់ថាអញ្ចឹង ខ្ញុំថាអញ្ចឹងសំរានលើអិដ្ឋណឹងទៅ អិដ្ឋការ៉ូណឹង គាត់ថា អើហ្អែងចេញសិន ដល់ចេញសិនទៅ គេហៅពួកខ្ញុំចេញទៅក្រៅអស់អាលីងអាណឹងមកថ្ងៃត្រង់ កាលណឹង៧៧ ខែ៨ តាស៊ីគេចាប់បាត់ហើយពីព្រឹកម៉ោង៨កន្លះណឹង កាលណឹងចាប់រាប់មិនអស់ទេ

ឃីម: ចុះបងឯងរួចខ្លួន?

សេង: រួច មុននឹងរួចណឹង វាវេទនាមុនរួច ដល់ពេលអញ្ចឹងទៅគាត់ឲ្យខ្ញុំចេញទៅក្រៅ គាត់មកប្រហែលម៉ោង១០អត់បាយហូបចុះមិនដឹងបានណាឆ្នាំងណាពួកខ្ញុំគេដកចេញត្រឹបពីកូនង៉ែតទៅគេ ដកចេញទាំងអស់ អត់មាននៅទេ ចុះមន្ទីរឆ្ងាយប្រហែលបីគីឡូពីក្រៅ រកបានរកឆ្នាំងអត់ឃើញ គេក៏ហៅខ្ញុំមកវិញ គេគេអូខ្ញុំមកវិញ ថាឲ្យមក ខ្ញុំភ័យណាស់មិនយកធ្វើអីទេ

ឃីម: ចុះគេបំរុងយកបងទៅណាយកទៅណឹង?

សេង: យកទៅដាក់លផ្ទែក កំពង់ឆ្នាំ បន្ទាយលផ្ទែកណឹង

ឃីម: គេយកពួកបស្ទិបទាំងអស់នៅណឹងដែរ?

សេង: អត់ទេ ដាក់តែមន្ទីរ៨០១ ដាក់នៅភ្នំបាសិតខ្លះពកខ្ញុំណឹង ដល់ហៅខ្ញុំមកវិញខ្ញុំមកដាំបាយឲ្យគេហូបដល់ហូបហើយយប់ប្រហែលម៉ោង៧ គាត់ថា តាម៉ុកណឹងគាត់ថា ឲ្យអាសេងនៅ

ដេកនេះ វាមិនទៅបាញ់អីយើងចោលទេគាត់និយាយជាមួយនិរសាគេអញ្ចឹង ដល់ហើយខ្ញុំក៏ព្រួ ខ្ញុំនៅកៀនជញ្ជាំងចុះបន្ទប់នៅជាប់គ្នាអញ្ចឹង ហើបើកបង្អួតមិនព្រួផ្ទះថ្ម ខ្ញុំក៏នៅណឹងម៉ោង៨ គេឲ្យឡានដឹកទៅលង្វែក ពីម៉ោង៨ទល់ពីម៉ោងបីរសៀល ខ្ញុំឆ្ងល់គុកគេណឹងពេញអស់ហើយយ៉ាង គេចេះតែឲ្យនៅណឹង ខ្ញុំនៅ គេនិយាយទៅខ្ញុំស្តាប់បានថា ចុះខ្លាំងមកពី ៤០១ បញ្ជូនទៅនៅគេថាខ្ញុំចិន គេនៅក្នុងខ្ញុំកាំភ្លើងម្នាងមួយៗប៉ុនគេអត់មានថាម៉េចទេ ប៉ុនគេនិយាយទូរស័ព្ទខ្ញុំនៅក្បែរណឹង ខ្ញុំព្រួ គេសុទ្ធតែធ្វើរោងមួយនៅក្បែរសរសរចូល គេនិយាយថាខ្លាំង៤០១មួយទៅនៅ ខ្ញុំព្រួភ័យក៏ភ័យអស់ពីភ័យថា ចុះទៅម៉ាចង្កេះអត់មានយកខោអាវទៅ ដល់ពេលទាល់ច្រកចឹងដូចអត់សូវភ័យ ថាគង់តែស្លាប់នឹកឃើញអញ្ចឹងបើគេយកទៅអស់ហើយ ព្រោះអីមុនខ្ញុំអញ្ចឹងគេចាប់យាយលី ខ្ញុំឃើញដាក់ស្តែង យាយលីមុនខ្ញុំ ប្រពន្ធតាស៊ុណឹង គត់បង់ក្រមាសំយោកទៅដល់គេកន្ទ្រាក់វ៉ង យាយណឹងគ្រាន់គេចាប់កន្ទ្រាក់ងឹកគាត់ថា ខ្ញុំដឹងហើយប្តីខ្ញុំក្បត់បានជាបក្សចាប់ខ្ញុំ យាយលីថាអញ្ចឹង គាត់និយាយពីនេះទៅដើមស្វាយ ខ្ញុំនៅណឹងព្រួគេចាប់យាយលីណឹង បានជាគេអត់ទាន់ខ្ញុំចូលហើយគេចងមុខគ្រឹមគេដឹកឡានទោបាត់ទៅមួយសន្ទុះប្រហែលជាកន្លះម៉ោងគេចាប់ប្អូនមួយទៀត ប្អូនយាយលីណឹងពូហាន ពូហានណឹងប្រធានមន្ទីរ យកពូហានទៅទៀត កាលណឹងពូហានកំសត់ដែរ មានតែខោខ្លីនិងអាវយឺតគេចាប់ចឹងទៅគាត់ថា អេហ្វែងធ្វើមែនធ្វើលេងគាត់ថាចឹង គេថាធ្វើមែនធ្វើលេងម៉េចគេថាចឹងហ្វែងក្បត់មែនណឹង គេចាប់នៅណឹងនៅទល់ម៉ោង៧ព្រឹកណឹងបានគេដឹកទៅភ្នំពេញទៀត ហើយខ្ញុំនៅណឹងដែរ នៅណឹងដល់ម៉ោង៣រសៀលបានតាសៀង ពេទ្យកងពលទី១នៅភូមិភាគបស្ចឹមណឹងគាត់គេអូពីកោះកុងមកគាត់ថាឲ្យខ្ញុំចូលទៅក្នុងកន្លែងទៅវាមិនមែនខ្លាំងទេ គាត់បញ្ជូនមកទេ គាត់ថាអញ្ចឹងព្រោះអីគាត់ធានាជាមួយតាម៉ុកថាបើមានព្រឹត្តិការណ៍អីផ្សេងៗមានបំផុសចលនាធ្វើសកម្មភាពអីយកគាត់បាញ់ចោលចុះតាសៀនគាត់ថាអញ្ចឹងព្រោះអីវាអត់មានដែលទៅណា បស្កាល់ស្អីគេហ៊ីហានឹងគេក៏អត់ដែរ ដូចនៅគុកអញ្ចឹងបើក្បត់ទុកគាត់ គេក៏បញ្ជូនខ្ញុំចូលទៅនៅម៉ោងបីរសៀលណឹងទៅដល់កន្លែងអត់មានអីគេឲ្យទៅបកប្រែទូរលេខណឹងទៀត បកនៅលង្វែកប៉ុនមុននឹងបានទៅថាបកនេះ កាលណឹងយប់ជំនាន់អាពត តែយប់គេយកទៅបាញ់ចោលហើយ កាលណឹងជំនាន់ណឹងខ្ញុំមាននាឡិកាអីដែរ ម៉ោង១២គេមកគោះទ្វហៅខ្ញុំថាអញទៅតែប៉ុណ្ណឹង ច្បាស់ជាគេយកទៅបាញ់ចោលទាំងយប់ណឹង តែអត់មានបើកទ្វារទេបើកបង្អួត

ថាមិនស្រួលលោតតាមបង្អួចឲ្យគេបាញ់ចោលខ្ជិលឲ្យគេយកទៅដាក់គុក ចុះបើឃើញយប់ឡើងស្រែក អ្នកខ្លះអត់មានខោអ្នកខ្លះអត់មានអាវមួសខែហើយកន្ទះខែអីគេឲ្យមុជទឹកម្តងព្រុគេថាអ្នកទោសណឹងគេស្រែកព្រលានរំពង ចុះភ័យអញ្ចឹងមានដេកលក់អី បើកបង្អួតបានគេប្រាប់ថាអត់ទេ កេឲ្យមក៤០១វិញព្រោះអីអត់មានអ្នកណាបកប្រែរួចពីមជ្ឈឹមទៅគេបន្ទោសហីក៏វាភ្លាមៗម៉េសបើអត់ទាន់មានអ្នកណា គេបង្រៀនផងគេថាអញ្ចឹង បើដកវាចេញមួយខាតច្រើនណាស់យកវាមកវិញ យកវាមកបង្រៀនឲ្យចេះសិនប្រាប់តាប៉ាល់ណឹងអញ្ចឹងគេក៏ប្រាប់ ខ្ញុំក៏ដេកទល់ភ្លឺម៉ោងបួនក៏គេមកហៅដឹកពីលង្វែកយកមក៤០១វិញ នៅបស្ចឹមវិញទៅនៅណឹងវិញ តាប៉ាល់គាត់ចេះនិយាយឲ្យខ្ញុំល្អដែរណឹង គាត់ថាហ្អែងនៅជួយធ្វើការ ជួយបង្រៀនឲ្យគេចេះទៅ តែគ្មានទឹកចិត្តបង្រៀនគេទេ

ឃីមៈ បងស្គាល់តាប៉ាល់ច្បាស់ទេ គាត់នៅណា?

សេងៈ តាប៉ាល់ណឹងផ្ទះគាត់នៅកំពង់ស្ពឺ

ឃីមៈ ចាំឃើញមានសំបុត្រមកពីកងពលដាក់ឈ្មោះប៉ាល់

សេងៈ អ៊ំប៉ាល់ណឹងគាត់ចាស់ហើយ អាយុ៧០ជាងហើយ ហើយតាស៊ីណឹង បងឪ ខ្ញុំទៀតឪខ្ញុំជាង៧០ហើយ បើនៅចាស់ហើយ គាត់ថា បើហ្អែងទៅអញមានអាណាចាក់ថ្នាំ តាប៉ាល់ណឹងគាត់ចាក់ថ្នាំម៉ាខែម្តងរោគថ្លើម ចាក់ត្រង់ឆ្អឹងជំនី បើល្មមមិនឲ្យចាក់ទេ កាលណឹងធ្វើជាប់ស្ងាត់ដែរណឹង វះអីល្មមធ្វើតែគ្នាឯង ខ្ញុំថាអត់ទេ នៅតែម្នាក់ឯងហើយគេសុទ្ធតែនៅភូមិភាគនិរតីទាំងអស់ គេទៅនៅណឹងបស្ចឹកគេដកអស់ហើយ កន្លែងខ្ញុំណឹងមានឡាំងថ្នាំមានទូថ្នាំ អាពួកដែលត្រូវក្អួយតាស៊ីណឹងបង្កើតជីដូនមួយចុះតាស៊ីណឹងស្រុកគាត់នៅកំពង់ចាមខ្ញុំធ្លាប់ទៅផ្ទះគាត់ណឹងបានពីរបីដឹងដែរ គាត់ឲ្យទៅលេង ពេលយកទៅណឹងប្រកែកពេញឡានទាំងអស់ គេថាដឹកដាក់ភ្នំបាសិតណឹងចុះកានីន បាលរូគីនអីថ្នាំគ្រុនចាញ់ វាឃើញក្រហមៗវាអកទាំងដៃៗវាថាអត់រស់ក្មេងៗអស់ណឹងវាដឹង វាគាស់ទូណឹងយកថ្នាំអាខ្លះផាប់លើឡានអាខ្លះអីទេ ក្មេងៗដាក់ភ្នំបាសិតចាស់ៗដាក់លង្វែក

ឃីមៈ តាមមើលទៅប្រហែលជាប៉ុន្មានពាន់នាក់ម៉ាមន្ទីរ៤០១ណឹង

សេងៈ រាប់ពាន់ ព្រោះអីពួកនៅកំពង់ស្ពឺនេះផងកន្លែងការ៉ាស់ឡាននេះ ច្រើនណាស់ជិតទាំងអស់បែបគេស្មានតែខ្ញុំស្លាប់អាអ្នកនៅជាមួយគ្នា ខ្ញុំក៏ស្មានគេស្លាប់ ខ្ញុំអត់ដែលស្រាវជ្រាវដែរ

អ្នកនៅភូមិភាគនិរតីណឹងក៏អត់ស្គាល់ខ្ញុំ ដល់ពេលបង្រៀនណឹងបាន២ខែដែរ តាម៉ុកយកអ្នកអត់ចេះអក្សរបង្រៀនលិចភ្លេចកើតបង្រៀនកើតភ្លេចលិចបកប្រែបកមិនកើតចុះវាអត់ចេះសរសេរអក្សរមិនត្រូវផងដល់ពេលនេះខ្ញុំថា ខ្ញុំឈប់ហើយបង្រៀនមិនចេះទេរើសអ្នកចេះបន្តិចមក គេថាពួកអនុធនអាងអីរកអ្នកចេះ អ្នកអត់ចេះណឹងហើយធ្វើការងំហ្មត់ចត់ ខ្ញុំថាបើរើសអ្នកចេះខ្ញុំសុំទៅលផ្នែកវិញហើយ តាប៉ាល់គាត់ចេះតែយាត់ ម៉ាអាទិត្យហើយម៉ាអាទិត្យទៀត ខ្ញុំថាអត់ទេអុំ ទៅលផ្នែកណឹងទៅកន្លែងបកប្រែទូរលេខវិញគេអត់យកទៅដាក់គុក ខ្ញុំអត់មានបានចូលគុកនឹងគេទេ ថាអញ្ចឹងសំណាងវងកាលនេះក៏អញ្ចឹងដែរ កាលនៅពេទ្យ១៨នាក់ ១៦នាក់កេចាប់បាត់នៅសល់តែខ្ញុំក៏អត់មានចំលើយថ្ងៃដែលគេត្រូវប្រជុំផែនការគេក្បត់ខ្ញុំទៅប្រចាំការសាលា គេសារ៉េមើលតាមឯកសារគេ គេថាវាអត់នៅមែន ហីមានភស្តុតាង ពួកធំៗដូងគណៈតំបន់ កងវរៈអី គេថាវាមែនវានៅប្រចាំការសាលានោះមិនបាននៅប្រជុំនេះសុំឲ្យវារួចខ្លួនភាគមតិច្រើន ហើកាលណឹងក៏អញ្ចឹងដែរ

ឃឹមៈ ចុះបងដឹងថាគេសំលាប់តាំងពីសម័យណឹងម៉េស សម័យអាពត?

សេងៈ ដឹង ទៅពីណឹង ឃើញផ្ទាល់ភ្នែក អស់សង្ឃឹមត្រឹមតាសួនណឹង ចុះតាសួននិងខ្ញុំគាត់ឈឺអីបន្តិចក៏គាត់ហៅខ្ញុំទៅចាក់ថ្នាំដែរ គាត់ស្រឡាញ់ថាហ្អែងដូចកូនដូចចៅអញ្ចឹង ចាប់ហើយ

ឃឹមៈ ចុះបន្ទាយលផ្នែកណឹងគេធ្វើអីខ្លះ?

សេងៈ ខ្ញុំអត់មានដើរទៅណាទេ ខ្ញុំនៅតែផ្ទះបកប្រែទូរលេខណឹង អត់ដឹងមានអីទេព្រោះអីយើងគ្មានសិទ្ធ តែចេញទៅក្រៅក៏អត់មានឲ្យអ្នកណាស្គាល់ដែរតែចៃដន្យថ្ងៃណឹងអាបូរាណកូនប្រសារតាម៉ុកភ្លៀង១ថ្ងៃណឹងអត់មានអ្នកណាដាំបាយ ចុះស្រុកនោះល្ងង់ណាស់អត់ចេះដាំស្លអីហូបទេ គេហៅខ្ញុំទៅឲ្យជួដាំបាយម៉ោង១០យប់ហើយ ខ្ញុំក៏ដាំបាយឲ្យគេមួយឆ្នាំ២កំប៉ុងកន្ទហគ្នាគេពីរបីនាក់ ធ្វើម្ហូប ហើយអត់មានអ្នកលើកបាយឲ្យគេទៀត ពូសំណាងប្រធានកងពលប្រើខ្ញុំលើកបាយឲ្យគេ ដល់លើកទៅបូរាណគេណឹង គេថាអានេះមកសង្ខមធ្វើធំយូរហើយ អានេះខ្លាំងគេថាអញ្ចឹង ខ្លាំង៤០១ ម៉េចមកបង្កប់ខ្លួននៅនេះ អានេះមកសង្ខំធ្វើធំយូរហើយ ហើយពូប្រធានមន្ទីរគាត់ថា ធ្វើធំអីវា វានៅតែបកប្រែទូរលេខហីពេទ្យកំប៉ិចកំប៉ុក គ្រាន់អុំអីឈឺហៅវាទៅព្យាបាល គេថាអត់ទេ គេធ្វើនយោបាយពូសំណាងគាត់ថាអញអត់ឲ្យទៅទេ គាត់ណឹងពួកម៉ាកជាមួយបូរាណណឹង ព្រោះអីខ្លាចបង ព្រោះអីពូសៀង

គាត់នៅកោះកុងបងស្អីថាឲ្យយកមកទុកណឹងហើយ គាត់ថាម្នាក់ណឹងគាត់ធានាបើក្បត់អី ឲ្យយកគាត់បាត់ចោលទៅ គាត់ធានាក្បាល់គាត់ ដល់ហើយបូរាណណឹងគេថា អត់ទេអង្គការរៀបចំភូមិភាគដែលធ្លាប់នៅស្រុកកំណើតភូមិភាគណាទៅនៅភូមិភាគណឹងវិញ គេនយោបាយអញ្ចឹង ពូណឹងថាអត់ព្រមចាំទូរស័ព្ទ អាចុកាលណឹងគេវៃទូរលេខទៅដើណឹងវៃទៅមានទាន់ណា បូរាណណឹងគេថា អត់ទេបញ្ជូនទៅភ្លាមៗ ក៏គ្នាណឹងក៏ស្មានថាបញ្ជូនទៅធ្វើការនៅតាកែវនេះមែន ដល់បញ្ជូនមកផ្ទះខ្ញុំនៅណឹង គេអត់មានឲ្យ មកគេបញ្ជូនទៅតាកែវទៅដល់តាកែវ អាពេទ្យតាកែវដែលធ្លាប់រៀនជាមួយគ្នាវគ្គកំនពេញណឹងគេស្មានថាខ្ញុំ ផ្លាស់នៅតាកែវជាមួយគេ អាគ្រូៗកូនតាម៉ុក គេនាំខ្ញុំដើរមើលកន្លែងផ្ទះជំងឺទូទៅ អត់ដឹងថាខ្វាអអីហើយក៏អត់មាន គេដើរមើលទេសភាពគេ ចុះកាលនោះគេឲ្យជួយពិនិត្យអញ្ចឹងដូចថាអាណឹងមានអ្នកជំងឺគ្រប់ខែហើយវាលើសឈាម គេឲ្យវិនិច្ឆ័យជំងឺជាមួយគេណឹង ដល់ស្រាប់តែមកវិញថ្ងៃរសៀលស្រាប់តែបូរាណគេខឹង គេបោះឲ្យប៊ិចមួយសៀវភៅមួយថាហក ធ្វើប្រវត្តិរូបខ្លួនឯងទៅ មានផែនការក្បត់អីខ្លះ រាយការណ៍បានអាគ្រូវាដឹង

ឃីម: អាគ្រូណឹងកូនតាម៉ុក ប្រពន្ធបូរាណណឹង

សេង: កូនតាម៉ុក ប្រពន្ធបូរាណអាជិច ប្រពន្ធពូវ៉ែនកងពលដែរ

ឃីម: កូនតាម៉ុកសុទ្ធតែមានប្តីមានប្រពន្ធអស់ហើយ ចុះបូរាណណឹងធ់អី?

សេង: បូរាណណឹងមិនដឹងធ្វើស្អី បែបនៅមន្ទីរគេណឹង

ឃីម: ដល់ឲ្យធ្វើជីវទស្សន៍ម៉េចទៅបង?

សេង: ខ្ញុំអត់ធ្វើ ខ្ញុំថាមិនដឹងមានផែនការក្បត់អី ខ្ញុំមានតែបំរើ អង្គការ បើថាមានផែនការសំលាប់អានេះអានោះ ខ្ញុំដឹងឆ្លើយថាម៉េច គេដាក់សៀវភៅឲ្យម៉ាអាទិត្យម៉ាថ្ងៃកេមកមើលម្តងៗ មើលទៅខ្ញុំអត់មានសរសេរអីមាត បាយខ្ញុំអត់សុវហូបដែរ នឹកឃើញថាមិនរស់ម៉ាថ្ងៃខ្ញុំហូបបាយតែពីរបីស្លាបព្រា ខ្ញុំមកអង្គុយអត់មាត់អត់ក នៅកន្លែងបុគ្គលិកគ្រូៗណឹង ប្រធានៗគេ

ឃីម: កូនតាម៉ុកណឹងរៀនពេទ្យបានច្រើន?

សេង: រៀនបានច្រើនដែរ ស្រី ឆែបមាត់ អាគ្រូប៊ុនឈ្មោះគេ អាលីន កាលមុនមកការ កូនផ្ទះលិចនេះ កូនពូឈៀងនេះ មកការពីរថ្ងៃ នៅលង្វែក លែងឆែបហើយតែនិយាយនៅ

ក្រដួរ និយាយខ្ទប់ៗគេនៅស្គាល់ខ្ញុំដែរនឹង គេមាន ។ ដល់អញ្ចឹងទៅខ្ញុំអត់មានធ្វើគេថា អញ្ចឹងបញ្ជូនវាទៅសាធារណៈការបូរាណថាអញ្ចឹង បញ្ជូនៗមកខ្ញុំអត់មានអីទាំងអស់មានតែម៉ាប្លាស់និងក្រមាមួយ វេទនាដល់បញ្ជូនមកឲ្យខ្ញុំធ្វើពេទ្យនៅសាធារណៈការ ពេទ្យស្លាគូពេទ្យសំរាប់អ្នកទោស គេឲ្យខ្ញុំធ្វើពេទ្យណឹងបើកតែថ្នាំដបតាកក្រួចគេមានស៊ិចនឹង បេអង់វិទាមីនសេថ្នាំគេហើបក៏ចាក់អាណឹង ចុកពោះក៏ចាកអាណឹងស្អីក៏ចាក់អាណឹងដែរ ខ្ញុំថាខ្ញុំអត់ចេះ ដើរយូរៗគេមាឲ្យដើរទៅណាចុះបបរលាយដំលូងមី ពោតហើយស្លតែដ៏ឹទិងត្រកួននៅកន្លែងសាធារណៈការស្លាគូណឹង ខ្ញុំនៅណឹងប្រហែលម៉ាខែ ស្លាប់ម៉ាយប់ ជួនកាលក្មេងមកពីភូមិភាគបស្ចឹមពាយ័ព្យបូព៌ា ម៉ាយប់ជួនកាល ៥០នាក់ ក្មេងៗវាហើម វាអត់ជីវជាតិ ខ្វះជីវជាតិដឹកយកទៅចំការដូងខាងលិចថ្នល់ណឹង កប់ណឹងដឹកត្រឹមណឹង អាណាទៅដឹកបានបើពេទ្យអត់មានបាយស៊ីដែរ ដឹករទេះសេះទៅកប់នៅរណ្តៅ

ឃីមៈ ស្លាគូនៅឃុំអី?

សេងៈ ស្លាគូដូចនៅខាងកំពង់ស្ពឺ នៅខាងលិចថ្នល់

ឃីមៈ សាធារណៈការសមរាប់គុក?

សេងៈ សំរាប់គេអប់រំ អ្នកមានទោស គេឲ្យធ្វើកំណត់កន្លែងណឹងដូចថាយើងមានវិបត្តិគេបញ្ជូនដាក់កន្លែងណឹង គេឲ្យយើងធ្វើស្រែ សុទ្ធតែជនសង្ស័យគេប្រមូលដាក់ម៉ាដុំ យកមកពីបូព៌ាពាយ័ព្យ មកច្រើនណាស់គ្រប់ភូមិភាគ ច្រើនណាស់រាប់មិនអស់ទេ ។ដល់ពេលព្យាយយូរទៅសុំគេឈប់ ព្យាយមិនរួចទេ ស្អុមគេហូបបបរប៉ិនណោះ

ឃីមៈ ខ្ញុំចង់សួរកន្លែងអ្នកទោសគេឲ្យធ្វើម៉េចខ្លះ គេលត់ដំម៉េចខ្លះ?

សេងៈ ស្ទូង ម៉ាហិចតាឲ្យស្ទូងតែ៩នាក់ទេ ពេញឲ្យគេ តែបានអីហើយបើខ្លះអត់ចេះផង ដូចខ្ញុំមានចេះអី អត់ហើយគេថាដកចេញខ្លះ នៅសល់៧នាក់ ៧នាក់រិតអត់ពេញទៀតស្អែកឡើងទៅស្ទូងណឹងទៀតគេថាមេបានដាមកស្ទូងណឹងទៀតគេវ៉ាស់ដីឲ្យថ្មីចុះថ្មីម៉េបើណឹង អត់ទាន់ពេញផងឲ្យចោលដីណឹងគេរាយការណ៍ថាយើងតវ៉ា ខ្ញុំថាបើមិនពេញយកទៅណាទៀតយកទៅ ជីវិតសល់ពីរាប់ហើយគិតអីទៀត គេថាឥឡូវលែងឲ្យស្ទូងហើយចាប់ដកម្តង ដកម៉ាព្រឹកឲ្យបាន៥ដួន ខ្ញុំថាចាំតែបានតើឥឡូវយកធ្វើអីធ្វើទៅខ្ញុំដកបានតែ៥ដំបរ ចុះបើមិនដែលធ្វើ តាំងពីតូចមកខ្ញុំអត់ដែលធ្វើផង គេថាឈប់ឲ្យ បើដកៗមិនបានស្ទូងមិនបាន

អញ្ចឹងខ្ទាំងពេញទីហើយ ខ្ញុំថាខ្ទាំងពេញទីយកទៅណាយកទៅជិវិតសល់ពីងាប់ គេពិសោធន៍ ទៅឃើញចេះតែគវ៉ា គេឲ្យខ្ញុំទៅនៅត្រាំខ្នាក្រុមណឹងគេលើករងដំឡូង កងសាធារៈការគេបំ បែកទៅណឹង លើករងដំលូងលើកមិនបានភាគច្រើន វាខ្សោយ មិនខ្លាំងអីហូបមិនឆ្អែតណា មួយគិតផងគ្មានបងគ្មានប្អូនទៅនៅម្នាក់ឯងតែមឹង នឹកឃើញបើគេហៅទៅ ស្លាប់គឺស្លាប់ រស់គឺរស់អត់មានឲ្យអ្នកនាដឹងទេ ហើយថ្នាំគេឲ្យដូចថាយើងឈឺមានពេទ្យគេទៀតផ្សំទុក បើ កុនខ្លាំងលេបឲ្យងាប់ហ្មងខ្លិលណាស់ ផ្សំបានច្រើនអត់ដែលមានលេបម៉ាគ្រាប់ទេ នៅត្រាំខ្នា ណឹងគេឲ្យលើករងដំឡូងលើកមិនបានច្រើននឹងគេ គេថាឥឡូវអត់ទេ ឲ្យដើរសុំទងគេតាម សហករណ៍វិញ ឲ្យខ្ញុំទៅបីនាក់ទៅសុទ្ធតែអ្នកប៊ិននិយាយដូចគ្នាឈ្មោះបងរុំនៅបូព៌ាមិនដឹង រស់ឬស្លាប់ទេបើរត់ទៅបែកគនា៧៩ បងរំគេថាគោះ បងរុំណឹងកាលគេនៅបូព៌ាឬពាយ័ព្យ មិនដឹងទេនេះបងរំណឹង គេកងទ័ពកងវរសេនាធំអីដែរណឹង ឲ្យបីនាក់ទៅសខ្ញុំថាចាំតែដឹកទៅ ទៅដល់សហករណ៍បញ្ចុះបញ្ចូលចុះឡើង១ឡានទៅចូលដឹកមានតែគេជួយកាត់ផង និយាយ ប្រូគេចុះឡើង១ គេថាអត់ទេ អាណឹងដាំបានច្រើនរកដីដាំលែងបាន ឥឡឹកអីពេញទួល អស់ហើយវាបានផលច្រើនគេថាឥឡូវបំបែកឲ្យទៅនៅដោះកញ្ឈរទៅដោះកញ្ឈរកន្លែងកុមារ ពេទ្យគេនោះ សុទ្ធតែព្រៃ ម៉ាខែឬពីរខែគេផ្តល់អង្ករឲ្យស៊ីម្តងអង្ករកន្ទះបាវរស់ដោយវេទនា បើគ្នាជាង១៥០នាក់មានស្រីប្រុសលាយគ្នាអត់អីហូប សុទ្ធតែព្រៃកន្លែង ពេទ្យកុមារជា តំបន់ គ្រូនចាញ់ គេបញ្ជូនទៅណឹងសុទ្ធតែអ្នកទោសដូចគ្នា គេឲ្យខ្ញុំធ្វើពេទ្យទៀតខ្ញុំមកបើក ថ្នាំទេថ្នាំដើបចំបក់ គេថាទៅបើកណា ខ្ញុំថាអត់ទៅបើក អញ្ចឹងទៅបើនៅកំពង់ស្ពឺ ខ្ញុំថាកពង់ស្ពឺខ្ញុំអត់ចូលទេ កន្លែងចាស់ខ្ទាសគ្នាឯង ក្រែងលោគេនៅ គេថាអត់១គេឲ្យនៅ កុមារពេទ្យអត់អីហូបខ្ញុំពុលក្តួចម៉ាថ្ងៃពីរបីដង ដោះកញ្ឈរណឹងឆ្ងាយណាស់ ទៅដល់កំពង ស្ពឺផ្លូវ ជាតិលេខបួន ប៊ិនកន្លែងណឹងជាកន្លែងអ្នកទោសទៅធ្វើចំការនៅណឹងដល់៧៨ខែ ១២ បងរុំពួកណឹងគេថា ចាំមើល៧៩សិន ខ្ញុំថា៧៩ម៉េច ចុះឥឡូវយើងគិតម៉េចថាពួក យើងឈឺច្រើនណាស់សុំផ្លាស់ទៅនៅស្លាគូវិញព្រោះអីដល់ខែណឹងស្លឹកឈើរង្គើះវាត្រូវចា ញ់ខ្លាំងយើងធ្វើសំបុត្រសុំគេមកវិញគេក៏យកឡានទៅយកមកវិញទាំងអស់គ្នា អត់មានអ្នក ណាស្លាប់ទេ ព្រោះអីថ្នាំឬសឈើឬសព្រៃចេះតែនាំគ្នាហូប ខ្ញុំអីណឹងធ្លាប់ស្គាល់ថ្នាំខ្លះផ្សំឲ្យ គេដឹកទៅគ្មានប្រធានកងអ់ទេ ព្រោះសុទ្ធតែអ្នកធំទាំងអស់ហើយ អ្នកណឹងសុទ្ធតែចោទក្នុង ការពាក់ព័ន្ធដូចគ្នា អត់មានកងមានក្រុមទេទូទៅទាំងអស់គ្នាម្ចាស់ការទាំងអស់គ្នាអត់មានអ្នក

ណាត្រូតអ្នកណាទេ    គេប្រលែងចោល    គេទៅយកមកថ្ងៃខែ១២ប៉ុនមិនដឹងថ្ងៃទីម៉ានទេ
យកមកដល់ស្វាគូ  គេឲ្យប្រូតកេចេះតែវ៉ាស់ដី  ហើយខ្ញុំចេហតែថាលេងចុះជិតចូលដលខែមួ
យហើយ  ខ្ញុំថារើយបើរត់ទៅយកសាក់កាដូគ្នាទៅផងកាលណើងមានអាវមួយខោមួយក្រមា
មួយគាត់ផ្ញើរយកទៅឲ្យ  ខ្ញុំគេឲ្យប៉ុនក្រុមពួកខ្ញុំណើងអត់មានមេមានកើយទេ  ដល់ហើយគេ
ប្រជុំថាឥឡូវបើអ្នកធ្លាប់ធ្វើទ័ពសុំឲ្យធ្វើទ័ពវិញ  អ្នកធ្វើពេទ្យសុំឲ្យធ្វើពេទ្យវិញ  ពួកខ្ញុំគេឡើង
តវ៉ាឈ្លុលអ្នកមានចេះខ្លាច  អ្នកទោសអត់ចេះខ្លាចទេពួកណើងអត់មានយកទៅសំលាប់ចោល
ទេ ប៉ុនវាដឹងព្រឹត្តិការណ៍គ្រប់គ្នា តវ៉ាថាកាលនៅសង្គ្រាម យកអញទៅបាញ់ដល់ពេលឈ្នះ
កាលណាយកដាក់គុក កុំរើយតវ៉ាអញ្ចឹង កាលណើងតាសុក តាអីទៅប្រជុំ គេថាពួកនេះបា
នយកទៅបាញ់ចោលទាំងពូជ  ហើយពួកណើងតវ៉ាថាបើបាញ់ៗទាំងពូជកុំឲ្យសល់មួយ  ឥឡូវ
បើថាទៅធ្វើស្រែ  លែងធ្វើទ័ពធ្វើអីហើយ  ឥឡូវប្រសព្វខាងកាប់ដីវិញនេះ  ចាំមើលលោក
អ្នកធំណើង   គេធលាប់បានដំណែងខ្ពស់ណើងឲ្យគេទៅធ្វើម្ដងមើលឈ្នះឬចាញ់ពួកអញដេកចាំ
មើល  ដើរចេញរុញជាងម៉ាពាន់អ្នកអត់មានអ្នកណានៅស្ដាប់អាលីង  ប្រធានណើងអត់មាន
ថាអី  ពូណើងស្លាប់បាត់ហើយ  ពូណើងដឹងពួកខ្ញុំអញ្ចឹងក៏ឈប់ទៅ  ពួកខ្ញុំណើងត្រូវត  បើបបរ
បើសិនណា   អត់មានអីបើថាចូលរុញអីចឹងពួកខ្ញុំចាក់ចោលអត់ហូបទេ   សុខចិត្តដេកអត់ម៉ា
ក្រុមណើងសាមគ្គីគ្នារស់ទៅបើឃ្លានត្របែកមួយចែកគ្នាបួនដប់នាក់  ក៏ចែកគ្នាដែរ  បើខឹងគេ
ចាក់ចោលឈ្លុចដើរចេញរុញអត់ស៊ី   ៧៩ណើងបែកកំពុងប្រូត   ម៉ាកងហាគ្នា៣០នាក់ណើង
កំពុងប្រូតជាមួយខ្ញុំ  គេថាបងទៅណាវិញ  ខ្ញុំថាផ្ទះនៅណាទៅណើងទៅ  គេថាបងឯងផ្ទះនៅ
ណាផ្ទះអញនៅជិតៗណើង  យើបងឯងដូចមកពីឆ្ងាយ  ឆ្ងាយស្គាល់ដីច្រើនមែន  តែផ្ទះ  អញ
នៅនេះទេខ្ញុំថាចាំយប់បន្តិចឆ្លងថ្នល់ជាតិទៅលិចវិញ  ផ្ទះអញនៅលិចទេ  ស្រាប់តែម៉ោងបួន
ថ្ងៃរសៀល   ស្រាប់ឡានមកពីណាតាមថ្នល់ជាតិលេខបី   មកចូលស្វាគូវៀតណាមខ្លះខ្មែរខ្លះ
តាមួយខ្ញុំស្មានតាស់ខ្ញុំភ្ញាក់ព្រើត     ឃើញទាបជិះឡានអាស៊ីប     តាស៊ីណើងទាបកច្រិចៗ
ពួកគេអត់ហ៊ានចេញទេ  ខ្ញុំចេញទៅឈរកន្លែងថ្នល់ណើង  គាត់ថាផ្ទះនៅណាទៅណើងទៅលែង
ប្រូតលែងអីខ្ញុំក៏ទៅប្រាប់ពួកណើងវិញថាផ្ទះនៅណាទៅណើងទៅបងរុំគេឡើងជិះឡាន   ឡានឈ
គេអូសខ្ញុំថាតោះទៅពាយ័ព្យទៅធ្វើការឲ្យពួកយើងវិញកុំនៅឲ្យពួកនេះ  ប្រើតាមចិត្តខ្លះនៅបូ
ព៌ណើងអូសរយៈដៃរយៈដើងខ្ញុំថាផ្ទះហ្អែងនៅណាទៅណើងវិញទៅ   ខ្ញុំទៅផ្ទះខ្ញុំវិញហើយទៅ
មើលម៉ែឪបងប្អូនបើតាំងពី៧៨មកខ្ញុំមិនដែលស្គាល់ផ្ទះម៉េចផងមកជាមួយខ្ញុំណើង     មកម៉ា

កងហា ដើរតាមរហូតឆ្លងថ្នល់ ក៏ពួកហ្នឹងអត់មានធ្វើអីបាបអីដែរ ពួកប៉ុលពតនៅខាងថ្នល់ អត់ហ៊ានដើរនាំគ្នាហែលទឹកសាគួហ្នឹងផ្លូវវាបត់បែនហ្នឹងច្រើន ហែលមិនគិតតួចតាំងពីម៉ោង ៧ ឆ្លងមកខេត្តកំពង់ស្ពឺ មកជួបផងខ្ញុំនៅកំពង់ស្ពឺ ពួកហ្នឹងចេះតែដើរតាមខ្ញុំទាំងអស់ ពួកភាពហ្នឹងគេហៅខ្ញុំទៅកំពង់ស្ពឺ ខ្ញុំថាអត់ទៅទេផ្ទះខ្ញុំនៅតាកែវ ក្រែងនៅបស្ទឹមគេថាអញ្ជើងខ្ញុំមកផ្ទះម៉ែឪខ្ញុំនៅតាកែវ មកដល់ជួបនារីមកតាមខ្ញុំហ្នឹង៦នាក់ទៀតធ្លាប់នៅមួយធ្លាប់ទុកចិត្តគ្នាផ្ទះគេនៅ១០៦ នារីហ្នឹងគេទៅតាមកងវិញទៅបើនៅជាមួយគ្នាបានអីហូប

យឹមៈ ចុះបងនោសាធារណការគេមានដែលបង្រៀននយោបាយអី?

សេងៈ អត់ ទេ ខ្ញុំធ្វើពេទ្យតែព្យាយសំបកដប មកបើកនៅដើមចំបក់ហ្នឹង

យឹមៈ នៅតាកែវមានពេទ្យច្រើន?

សេងៈ ច្រើន តែខ្ញុំអត់មានស្គាល់គេណា ខ្ញុំគ្រាន់តែគេណែនាំបុគ្គលិកគេផ្នែកអីៗ

យឹមៈ ចុះមានដែលគេនយោបាយអប់រំដល់ជនសង្ស័យហ្នឹងទេ?

សេងៈ អត់ទេ យកមកប្រលែងចោលឲ្យធ្វើការដាក់កំណត់ ដាក់កំហិតបើយើងធ្វើមិនបានគេ

យឹមៈ ខ្ញុំចង់សួរបងសារដើមបន្តិច កន្លែងពេលបងរែកហើយសុំគេចូលរៀនពេទ្យ ពេលចូលរៀនពេទ្យហ្នឹងប៉ុន្មាននាក់ ឆ្នាំណា?

សេងៈ រៀនពេទ្យហ្នឹងឆ្នាំ៧៨ ខែ៧

យឹមៈ ចុះដំបូងចូលរៀនពេទ្យអីគេ?

សេងៈ ពេទ្យតំបន់ដីឆ្នាំងគេ គេហៅពេទ្យតំបន់ហ្នឹង ពេទ្យហ្នឹងពូហ្នឹង ពូគ្រិន

យឹមៈ គ្រិន លាន មែនទេ?

សេងៈ មិនដឹងម៉េចហៅគាត់តែពូគ្រិនៗ រាងតួច កច្រិចៗ ប៉ុនស្លាប់បាត់ហើយ ស្លាប់ដោយប្រតិកម្មថ្នាំខ្លួនឯង យាយក៏ស្គាល់ដែរ

យឹមៈ អូរមិនមែនទេ ចុះបុគ្គលិកនៅពេទ្យតំនប់ហ្នឹងប៉ុន្មាននាក់ សុទ្ធតែអ្នកចេះ

សេងៈ រាប់រយ ច្រើនចិន

យឹមៈ ចិនមកពីស្រុកចិនហ្នង

សេង៖ ចិនមិនដឹងមកពីស្រុកអីទេ បើគាត់និយាយចិន មកបង្រៀនផងដាក់ស្តែងផងគេខាងម្ជុលវិជ្ជាវិទ្យាសាស្រ្តដូចត្បាល់ ក្បាលជន្លង់អីណឹង ខ្ញុំក៏រៀននៅណឹងដែរ

ឃីម៖ ចុះបងរៀនរយៈពេលប៉ុន្មានខែ?

សេង៖ នៅច្រើន នៅយូរឆ្នាំ ដល់បែកហើយបានចេញពីណោង មានគេបងហូ ប្រធានបច្ចេកទេសគេពូគ្រិន និងប្រពន្ធគាត់បងខេង តែបងខេនណឹងគេចាប់ដែរ

ឃីម៖ ចុះបុគ្គលិកប្រហែលប៉ុន្មាននាក់?

សេង៖ បុគ្គលិក ពីរបីរយ

ឃីម៖ មុនដំបូងគេរៀនណឹងធ្វើម៉េចខ្លះ?

សេង៖ រៀនវ៉ាស់ចាក់ថ្នាំ ត្បាល់ម្ជុលវិទ្យាសាស្រ្ត ចិនគេបង្រៀនខាងម្ជុលវិទ្យាសាស្រ្ត ចិនណឹងខ្ញុំស្គាល់តែបងហួងៗចេះខ្មែរ មុនដំបូងអត់ចេះសោះចាក់ខ្នើយ ចាក់ដើមចេក រៀនចាក់សាច់ដុំហើយ ចាក់សរសៃរ បន្ទាប់មកគេឲ្យចាក់អ្នកជំងឺ ចាក់អ្នកជំងឺធ្ងន់សុទ្ធតែកងទ័ពកាលឆ្នាំ៧៤ មានកងទ័ពនិងប្រជាជននៅជិតណឹងដែលគ្រុនចាញ់ ភាគច្រើនគ្រុនចាញ់

ឃីម៖ ចុះប្រជាជនមានរើសវណ្ណៈអីទេ?

សេង៖ អត់ទេ ឲ្យតែគេបញ្ជូនទៅពេទ្យណោងយើងមើលទៅ ដល់បែកភ្លាមណឹងគេឲ្យមកពេទ្យកងពលនៅកន្លែងចំពុះវ័ន្តកេឲ្យមកនៅណឹងជិតម៉ាឆ្នាំកាលណឹងគេត្រូវវះកាត់ច្រើន នៅក្រុមវះកាត់ជាមួយគ្នាណឹងដាងដប់នាក់ដែរ ពួកវះជាមួយគ្នាណឹង ពូកាន់ដុកទ័រធំ ឈ្មោះពូកាន់ហើយពូអន បូរ៉ា ស្រួច គ្នាច្រើនស្រីៗបួនប្រាំនាក់ណឹង ប៉ុន្មដុះគេគេច្រើននៅត្រពាំងធំគេអ្នកចេះ ខ្ញុំទៅដល់គេឲ្យមករៀនដាក់ស្តែងដូចថាវះអី ចូលក្នុងក្រុមជាមួយគ្នាគនា៦នាក់ដូចថាអ្នកជំងឺធ្ងន់ គេឲ្យយើងនៅអ្នកជំងឺធ្ងន់១២បន្ទប់

ឃីម៖ ថ្នាំមកពីណា?

សេង៖ ថ្នាំមកពីចិន ប៉ុន្តែថ្នាំច្រើនគ្រោះថ្នាក់ច្រើនព្រោះអីយើងបែកភ្នំពេញហើយថ្នាំមកពីបរទេសច្រើនយើងអត់ស្គាល់ បុគ្គលិកភាគច្រើនមិនសូវចេះអក្សរ ដល់អត់ចេះអក្សរដូចចាក់អញ្ចឹងដូចថា ឥឡូវយើងចាក់ថ្នាំស្ពឹក វាមិនប្រើថ្នាំស្ពឹកប្រើថ្នាំប្រទ្បាំ ប្រតិកម្មស្លាប់

ឃីម៖ ចុះតាគ្រិនណឹងប្រតិកម្មខ្លួនឯងម៉េច?

សេង៖ នៅពេទ្យ១៧ កាលណឹងទៅរៀនជាមួយគ្នាណឹងគាត់គ្រូនចាញ់ អាគីនីនលេខ៣០០ណឹង គេថា លេបម៉ាថ្ងៃបានតែពីរដងទេព្រឹកល្ងាច គាត់លេងឌុបម្តងបី គាត់ថាអញដុកទ័រយូរ អញលេបថ្នាំគ្រូនចាញ់អស់ចិត្តហើយ គាត់ថាអញ្ចឹង ប៉ុនកាលនោះគេហូបលាងក្រពះតែ សង្គ្រោះហអត់ទាន់ នៅ១៧ ហើយស្លាប់ទៅ ហើយប្រពន្ធគាត់គេថាខ្សែរយៈក្សត់ក៏គេចាប់

ឃីម៖ ចុះពេទ្យកងពលណឹងគេចែកជាផ្នែកៗដូចពេទ្យតំបន់ ចុះពេទ្យតំបន់មានប៉ុន្មានផ្នែក?

សេង៖ មានឆ្អប ទូទៅ វះកាត់ វះពិសេស ម្ហូលវិទ្យាសាស្ត្រ

ឃីម៖ ចុះចិនប្រហែលប៉ុន្មាននាក់មកជួយ?

សេង៖ ប្រហែល១០នាក់

ឃីម៖ មើលទៅចិនមកពីស្រុកចិន?

សេង៖ ចិនពេលជួបគ្នានិយាយចិន ចេះខ្មែរប៉ៃឡាំ ដូចខ្ញុំបានចេះណឹង ចេះតែសួរដេញដោលចេះ ឆ្លល់ យើងប៉ុនសួរគេ

ឃីម៖ ចុះបងមានស្គាល់ប្រធានមួយៗនៅពេទ្យតំបន់ណាទេ

សេង៖ ប្រធានមានតែបីនាក់ បងហូរៗកូនតាម៉ុកណឹង ហ៊ីពូគ្រិន បងខេងណឹង និងពេទ្យចល័ត កាលណឹងមានពេទ្យចល័ត មិត្តលឿនអ្នកបង្កាមានតែ៥នាក់ណឹង

ឃីម៖ ចុះមកពេទ្យកងពល?

សេង៖ ពេទ្យកងពល១២នាក់ ប៉ុនដូរវេនគ្នាមកម្តង ៦នាក់ ដូចគ្នានិងពេទ្យតំបន់ដែរ

ឃីម៖ ចុះប្រធានមានឈ្មោះអីខ្លះ?

សេង៖ ប្រធានណឹងមានពូកាន់ ពូអនណឹងនៅឆ្នាំ៧៥បែកហើយ

ឃីម៖ ចុះពេទ្យចំពុះវ័ន្ត?

សេង៖ ចំពុះវ័ន្តណឹងបែកភ្លាមមក ចុះយើងបែក៧៥ខែ៤ ខ្ញុំប្រហែលជាខែ៨ខ្ញុំមកពេទ្យចំពុះវ័ន្ត ព្រោះអីអ្នកជំងឺច្រើនគេហៅឲ្យមករៀនជាក់ស្តែងណឹង ហើយពួកម៉ាចំនួនត្រូវទៅរៀននៅ ១៧មេសាទៅជំនួយការនៅណឹង

ឃីម៖ ចុះពេលមករៀននៅពេទ្យ១៧មេសាណឹងមានគ្នាតែបីនាក់ទេ បងនិយាយគេដក១៨នាក់

សេង៖ ១៨នាក់ មកពួកខ្ញុំអាណឹងខ្ញុំចុះទៅបង្កើតពេទ្យអន្លុងជ្រៃ

យឹម៖ ចុះមករៀននៅពេទ្យ១៧មេសាវគ្គដំបូងណឹងគេឲ្យធ្វើម៉េច

សេង៖ វគ្គដំបូងមធ្យម ដំបូងគេឲ្យយកឯកសារ គេមកបង្រៀនពីដងខ្លួនមនុស្សយើងមានស្អីខ្លះ ហើយគេឲ្យទៅវិនិច្ឆ័យជំងឺ វិភាគជំងឺវិញ មុនដំបូងគេបង្រៀនពីសរីរាង្គកាយខ្លួនយើង រៀនទាំងអស់ណឹង សៀវភៅខ្ញុំមានទាំងអស់ប៉ុនខ្ញុំក្រវ៉ាត់ចោលកាលរត់ គេឲ្យរៀនពិនិត្យជំងឺអិ ដូចថាជំងឺមានរោគសញ្ញាអីខ្លះយើងវិនិច្ឆ័យថាម៉េចខ្លះ ព្យាបាលថ្នាំអី

យឹម៖ ចុះគ្រូណឹងឈ្មោះអី

សេង៖ បង្រៀនទូទៅពូសាត ពូសាតណឹងធាត់ទាបមិនដឹងមកពីណានៅពេទ្យ១៧ហើយពូអ៊ិនសូកាន ណឹងឈ្មោះពូនី អិនសូកានណឹងពេទ្យពីសង្គមចាស់ដែរ គាត់ខាងសួត ហើយបងថនប្រពន្ធពូសាតណឹងខាងឆ្អឹង វគ្គមធ្យមរៀនទាំងអស់រៀនទូទៅ គេរៀនគ្រប់មុខរៀនតាំងពីឆ្អឹងរបេង ណឹងពីទីណឹង អ៊ិនសូកាន វះកាត់តាប៉ែនណឹង ហីប្រពន្ធគាត់មិនដឹងឈ្មោះអី

យឹម៖ ខ្ញុំមើលឯកសារឃើញតាប៉ែនៗតែមិនដឹងថាដួន ជឿនទេ ចុះប្រពន្ធជនជាតិខ្មែរ?

សេង៖ បារាំង កូនគាត់រៀនវគ្គជាមួយខ្ញុំ បងហាន បងនាត ស្អាតសៗគាត់ពេទ្យនៅក្នុងណឹងហ្នឹង

យឹម៖ ចុះកូនដួន ជឿនណឹងចេះច្រើនទេ

សេង៖ មើលទៅប្រហែលៗគ្នារៀនជាមួយគ្នា គេចេះបារាំង គេបង្រៀនណឹងក៏អញ្ចឹងដែរ តាប៉ែនណឹងបារាំង ពេលបង្រៀននិយាយរ៉ូបារាំងដូចថាវះអី ដូចថាវះខ្នែងពីងមិនថាខ្នែងថាបារាំង ប្រពន្ធតាប៉ែនខាងពិសោធន៍ ខាងពិសោធន៍មេរោគ ពិសោធន៍ឈាម មិនដឹងពេទ្យអីខ្លះទេ ខ្ញុំមិនសូវចាំឈ្មោះគេទេ

យឹម៖ ចុះរបៀបរបបគេឲ្យយើងសិក្សាកាមទៅរៀនណឹងម៉េចខ្លះ?

សេង៖ ទៅនៅសិក្ខកាមនៅម៉ាជុំ ដូចម៉ោងគេកំណត់ចឹងម៉ោង៧ឡើងទៅ ម៉ោង៧កន្លះរៀនដល់ម៉ោង១១គេឲ្យយើងចុះដាក់ស្ដែងអ្នកជំងឺដូចថ្ងៃណឹងយើងរៀនខាងឆ្អឹងចុះទៅឆ្អឹង រៀនខាងសួត យើងចុះទៅខាងរបេង ដូចរៀនខាងរោគសង្គមគេឲ្យយើងទៅដាក់ស្ដែងខាងរោគសង្គមយើងពិនិត្យដាក់ស្ដែថាមនារោគសញ្ញាអីខ្លះ ហើយយើងត្រូវប្រើថ្នាំអីខ្លះព្យាបាលហីដល់រោគសញ្ញាជយនកាលយើងវិនិច្ឆ័យខុសដែរដូចថាខ្លះ ក្មេងតូចកើតរោគសង្គមយើងជឿតែអាយុ៨ឆ្នាំអាណឹងកើតពីណាមកអាណឹងគេឲ្យយើងទៅមើលអាណឹង យើងវិនិច្ឆ័យ

ថាក្មេងប៉ុនណឹងមិនអាចកើតរោគណឹងទេចុះការនឹងមានរោគស្វាយប្រមេះអីណឹងមិន ក៏មាន កើតបើទើបតែអាយុ៨ឆ្នាំ

យឹម: ចុះអ្នកជំងឺមកពីណា?

សេង: មិនដឹងយកពីណាខ្លះ ច្រើនកូនកម្មាភិបាលកូនអ្នកធំ ៗ

យឹម: ចុះកាលបងនៅពេទ្យតំបន់អ្នកជងឺសុទ្ធតែម៉េច

សេង: អ្នកជំងឺកងទ័ពខ្លះ ប្រជាជនខ្លះ សុទ្ធតែប្រជាជនចាស់

យឹម: ចុះប្រជាជន១៧មេសាអត់មានទេ?

សេង: អត់មានទេពេទ្យតំបន់សុទ្ធតែប្រជាជនចាស់

យឹម: ចុះពេទ្យចំពុះវ័ន្ត?

សេង: ចំពុះវ័ន្តមាន១៧ ច្រើនណាស់កាលណឹងកងចល័តបញ្ជូនទៅច្រើនណាស់

យឹម: ចុះយកចិត្តទុកដាក់ទេ យើងជាគ្រូពេទ្យ?

សេង: យកចិត្តទុកដាក់ធម្មតា ១៧ក៏អញ្ចឹង ចុះពូខ្ញុំ ១៧ដែរកាលណឹងខំតាមដានក្រែងលោពូខ្ញុំចេញមកពីភ្នំពេញដែរ ឃើញអ្នកជំងឺមួយៗខំមើលក្រែងលោពូឯងដែរ

យឹម: ពេលបងមករៀននៅពេទ្យ១៧ណឹងវិន័យគេម៉េចដែរចំពោះសិក្ខកាម?

សេង: វិន័យអត់មានឲ្យដើរហើ អត់មានឲ្យទាក់ទងអីទៅណាទៅណីទេ នៅកន្លែងណានៅកន្លែងណឹង ដូចថាពេលហូបបាយហូបទៅប៉ុននៅមានម៉ាចំនួយនៅមានលួចទាក់ទងគ្នា

យឹម: ចុះទាក់ទងអន្តការថាម៉េច?

សេង: ដូនកាលគេយកទៅបាត់ នៅពេទ្យចំពុះវ័ន្តក៏នៅមានយក តែពួកខ្ញុំចេហកសាងគ្នា អាណិតគ្នាជួយលាក់គ្នា នៅក្មេងៗដូចគ្នា ហើយខ្លះគ្នាមិនទាន់គ្រប់ការផង

យឹម: ចុះម៉េចចេះទាក់ទងគ្នា?

សេង: ចុះក្មេងៗគ្នាដឹងអី មានដល់ខូចសីលធម៌អី គ្រាន់តែនិយាយគ្នាណឹង មានលង់អីបើនៅស្រីដូចគ្នាយើងមិនដឹងថាក្រមុំមិនក្រមុំ គេចោទគ្នា ខ្ញុំចេះជួយគ្នាទៅ

យឹម: ចុះបើអន្តការដឹងរឿងសីលធម៌ដឹងធូន់?

សេង: ធូន់ តែបើអ្នកធំៗគ្នាគេអត់អី

ឃីម: ចុះពួកធំៗសីលធម៌ច្រើនទេ?

សេង: វាមិនច្រើនម៉ានទេ វាស្រឡាញ់គ្នា ដល់ហើយគេការឲ្យដែរណឹងតឹងតែងតែប្រជាជន ចុះគ្នាអាយុ២៥ ៣០ហើយមិនទាន់រកប្រពន្ធឲ្យគ្នាផង ដល់ហើយធ្វើការជាមួយគ្នាយូរៗទៅវានេះទៅ

ឃីម: ចុះនៅពេទ្យ១៧ណឹងមានអ្នកខុសសីលធម៌ច្រើនទេ?

សេង: អត់សូវមានទេ ព្រោះអីវាអត់មានអីហូបទេ មនុស្សយើងតែរឿងអត់ហូបអត់មានទេរឿងសីលធម៌

ឃីម: ក្នុងម៉ាថ្ងៃគេរៀនប៉ុន្មានម៉ោង?

សេង: ពីម៉ោង ៧ដល់ម៉ោង១១ចុះហូបបាយ ហូបបាយណឹងក៏វិន័យ គេតាំងដែរបើថា យើងត្រូវចុះម៉ោង១១ក្រុមយើងត្រូវហូបបាយដាក់វេនគ្នាហូប ហូបម៉ោង១១កន្លះតែយើងម៉ោង១២ចូលទៅគឺអត់បាយហើយវិន័យគេអញ្ចឹង បើក្រុមយើងជាប់ជាក់ស្តែងអ្នកជំងឺយើងមានឲ្យម្នាក់មកប្រាប់គេនៅផ្ទះបាយដល់ម៉ោងគេហូបបាយ ចុះកាលណឹងគេមាននាឡិកាពាក់គ្រប់គ្នាពេទ្យប្រាប់គេថា ក្រុមខ្ញុំអត់ទាន់ហូបបាយទេ ស្នើដកហូបពេលស្មានណោហវិញអាណឹងបានអត់មាមថាឥឡូវចង់ហូបៗទេ វិន័យតាំងគេតឹងណាស់ ពេលញាំបាយហើយគេឲ្យសំរាក ម៉ោង២កន្លះគេឲ្យចូលវិញចូលរៀនម្តងទៀត ដល់៤ល្ងាចឡើងយប់ម៉ោង៧គេឲ្យយើងមកពិភាក្សាគ្នា

ឃីម: ចុះយប់មានរៀននយោបាយ?

សេង: អត់ទេ នយោបាយម៉ាអាទិត្យគេរៀនម្តង គេរៀនពីរបៀបរបបរស់នៅសីលធម៌កុំឲ្យមានប៉ះពាល់

ឃីម: ចុះអ្នកណាគេបង្រៀននយោបាយ?

សេង: ឈ្មោះអីទេ ខៀវប៉ុណ្ណារិទ្ធ អ៊ំធាត់ទេនេះ

ឃីម: អូ ខៀវធារិទ្ធ ឬអៀងធារិទ្ធ

សេង: ខៀវធារិទ្ធ

យឺម: អញ្ចឹងមានតែប្រពន្ធអៀងសារី ចុះគេមកបង្រៀនម៉េចខ្លះ?

សេង: គាត់ធាត់មុខធំ គាត់និយាយរឿងកុំឲ្យយើងខុសសីលធម៌ឲ្យស្លូតបូតយកចិត្តទុកដាក់អ្នកជំងឺ អីណឹង កុំប្រកាន់វណ្ណៈឋានៈដូចពីមុនអីណឹង ម៉ាអាទិត្យគាត់ទៅបង្រៀនម្តង

យឺម: ពេលយប់គេឲ្យធ្វើអី?

សេង: យាមដូចថា ម៉ាបន្ទប់ម៉ាក្រុមៗប៉ុនម៉ាក្រុមប្រុសច្រើនស្រីភាគតិចជាង គេឲ្យគេង នៅបន្ទាយស្ទឹក

យឺម: ចុះចេញពីរៀនពេទ្យណឹងរយៈពេលប៉ុន្មានខែ?

សេង: កាលរៀនណឹងខ្ញុំមកវិញបាន ចប់វគ្គ៧៥ខែ១២ហើយបានខ្ញុំមកបង្កើតមន្ទីរពេទ្យនៅអន្លង់ជ្រៃ

យឺម: ពេលមកបង្កើតនៅអន្លង់ជ្រៃមានបុគ្គលិកប៉ុន្មាននាក់?

សេង: បង្កើតមុនដំបូងមានតែ៣ ៤ ៥នាក់ តាប៉ុនប្រធាន និងបូរ៉ាតដែលទៅរៀនស្រុកចិនណ៎ង

យឺម: អូ បូរ៉ាតដែលថាទៅរៀននៅស្រុកចិនណឹង

សេង: ចា៎ បូរ៉ាតទៅស្រុកចិនទៅតាមតាស៊ីទៅ អត់បានទៅតែខ្ញុំ ឥឡូវបែកគ្នាមិនដឹងនៅណាទេ កាលណឹងគាត់នៅពេទ្យអន្លង់ជ្រៃតាស៊ីយកមកតាមគាត់ទៅ

យឺម: បងនៅពេទ្យអន្លង់ជ្រៃបានប៉ុន្មានខែ?

សេង: នៅបានយូរដែរណឹង ប្រហែល៧៧បានខ្ញុំចេញពីអន្លង់ជ្រៃ ណឹងសុទ្ធតែព្រៃនៅភូមិភាគគេមានតែខ្លា មានអ្នកជំងឺប្រជាជននៅជិតណឹងគេធ្វើទំបន់អីណឹងប្រជាជននៅណឹងថ្នាំបើកនៅអបលាំង មានថ្នាំចិនខ្លះ មានថ្នាំធ្វើនៅណឹងខ្លះ

យឺម: កន្លែងពេទ្យបងនៅពេទ្យតំបន់ ពេទ្យកងពលមានកន្លែងធ្វើថ្នាំអីទេ

សេង: អត់ទេ

យឺម: ចុះមកពេត្យ១៧មេសាឃើញគេធ្វើថ្នាំទេ?

សេង: អត់មានដែលមេលគេជងកន្លែងធ្វើថ្នាំគេអត់មានឲ្យយើងរៀនធ្វើថ្នាំទេរៀនតែរបៀបព្យាបាល

យឺម: មានដែលដើរក្នុងភ្នំពេញអីទេពេលយើងកំបងរៀន?

សេង៖ ពេលរៀនពេលបុណ្យ១៧មេសាគេឲ្យមកមើលសិល្បៈនៅស្តាតដើរមកពីពេទ្យ១៧ណឹង មើលសិល្បៈខ្មែរ

យឹម៖ គេលេងរបៀបម៉េច?

សេង៖ គេលេងរឿងយាយលូត កាយវិការចំរៀងមានកាបលអុសស្លៀកពាកខ្មៅ អីណឹង មាន តែអញ្ជឹង

យឹម៖ ចុះមានដែលមើលកុនទេ

សេង៖ អត់ទេ

យឹម៖ មានដឹងថ្ងៃសៅថ្ងៃអាទិត្យទេកាល?

សេង៖ អត់មានដឹងថ្ងៃអីទេ ថ្ងៃណាការធ្វើការអីដែរ

យឹម៖ អត់ទេ ចង់និយាយថាថ្ងៃនេះថ្ងៃច័ន្ទ អាទិត្យសៅអីយើងដឹងទេ ?

សេង៖ យើងមាននាឡិកា

យឹម៖ ប៉ុន្មានថ្ងៃគេឲ្យទៅមើលសិល្បៈម្តង?

សេង៖ ដល់ពេលមានបុណ្យ

យឹម៖ ចុះរបបហូបចុកគេឲ្យហូបម៉េចដែរ?

សេង៖ នៅ១៧ មានតែត្រកួន និងទំប៉ុង

យឹម៖ ចុះនៅពេទ្យតំបន់អីហូបគ្រប់គ្រាន់ទេ?

សេង៖ ហូបបបរ

យឹម៖ ចុះអ្នកជំងឺ?

សេង៖ អ្នកជំងឺអ្នកពិសេសអ្នកធ្ងន់ ទៅយើងមានហូបមានត្រីមានសាច់ជ្រូក មាន់ទាអី

យឹម៖ ចុះគេបែងចែកអ្នកជំងឺអីទេ អ្នកចាស់អ្នកថ្មី

សេង៖ អ្នកជំងឺអត់ទេអត់មានបែងទេ ពេទ្យចំពះវ័ន្តយកចិត្តតុកដាក់ទាំងអស់គ្នា

យឹម៖ ចុះអ្នកជំងឺចូលច្រើនទេ?

សេង: ច្រើន កាលឆ្នាំ៧៦ សម្តេចមកភំពេញ ចុះចំពុះវ័ន្តណឹងជិតភ្នំពេញដែរ កាលណឹង អ្នកជំងឺរកកន្លែងសំរានមិនបានទេពេញទាំងអស់កន្លែងអនុវិទ្យល័យចំពុះវ័ន្តណឹង ណែនប៉ុនខ្ញុំនៅក្មេងដែរ មិនសូវបានចាក់ថ្នាំអីផងគ្រាន់តែបូមយើងអ្នកចេះ ព្រលឹមដើរពិនិត្យជំងឺ ថាគ្រុនចាញ់ត្រូវវៃថ្នាំអីខ្លះទៅ ហ៏របួសនេះយើងត្រូវប្រើថ្នាំអី

ឃីម: ចុះខោងាវអ្នកជំងឺយើងបោកដែរ?

សេង: អត់ទេ

ឃីម: ចុះពេទ្យតំបន់ពេទ្យកងពលអី?

សេង: ណឹងក៏ ខ្ញុំមិនដែលត្រូវវេនបោកនឹងគេផង ចេះតែនៅកន្លែងអ្នកជងឺធ្ងន់ណឹងទៅនៅព្យាបាល

ឃីម: ចុះនៅពេទ្យចំពុះវ័ន្តណឹងម៉ាថ្ងៃធ្វើការប៉ុន្មានម៉ោង?

សេង: អត់មានម៉ោងទេ ដូចថាយប់ជួនកាលម៉ាយប់ទល់ភ្លឺអត់បានសំរាកទេ គ្រាន់អែបគេ

ឃីម: ចុះនៅពេទ្យចំពុះវ័ន្តណឹងធំដុំបច្ចេកទេសគេមានវះមានអី ?

សេង: វះពោះ កាត់ជើង មានអ្នករបួសថាត្រូវបាក់ជើង ប្រធានគេហៅអ្នកបច្ចេកទេសល្អមៗដូចគ្នា ខ្ញុំច្រើនគេប្រើថ្នាំយកក្រដាស យាមសារ៉ុមនិងយកឈាមមិនដែលកាន់កាំបិតនិងគេ

ឃីម: រយៈពេលប៉ុន្មានបានតាស៊ីហៅទៅ?

សេង: តាស៊ីហៅទៅបើកនៅអន្លុងជ្រៃ

ឃីម: ចុះប្រធាននៅណឹងអ្នកណាគេ?

សេង: តាប៉ុនណឹង មកពីស្រុកបារាំង ដុកទ័រស្រុកបារាំង ប៉ិនតាប៉ុនថ្នាំក៏ចេះធ្វើថ្នាំក៏ចេះធ្វើព្យាបាលក៏ចេះប៉ិនតាប៉ុនណឹងនៅបានយ៉ាំងយីរ៥ខែគេចាប់ គេហៅថាទៅរៀនៗស្រាប់តែបាត់តាប៉ុនណឹងរហូត ប៉ុនតាប៉ុនស្លូតណាស់

ឃីម: ចុះក្រៅពីតាប៉ុនគេចាប់ទៅអ្នណាគេឡើងជំនួស?

សេង: ក្រៅពីតាប៉ុនណឹងតាស៊ុំដកចេញហើយ

ឃីម: នៅជាមួយតាស៊ុំណឹងគេឲ្យធ្វើអីខ្លះ?

សេង: នៅតែព្យាបាលតាសីណឹងនិងបកប្រែតួលេខ ពេលនោះជួយអូសទស្សវដ្ដីគេទៅ

យឹមៈ ចុះបងថាសីហនុមកទៅមើលពេទ្យនៅចំពុះវន្តណឹង.

សេងៈ សម្តេចឪកាលណឹងខ្ញុំអត់បានទៅទេអ្នកជំងឺច្រើនពេកឈ្មោះខ្ញុំត្រូវទៅដែរ កាលណឹងគេ ចុះមកគេមានទទួល ដូចថាយុវជនយុវនារីធ្វើប្តីប្រពន្ធគ្នា ដើម្បីឲ្យសម្តេចឪណឹងថាមានប្តីមានប្រពន្ធប្រធានគេមកប្រាប់អញ្ចឹងហ្នឹង មិនដឹងពីណាកាលនោះអត់ហ៊ានដេញដោល ព្រោះអីខ្ញុំដាច់ដោយឡែកកាលណឹង៧៦ ខែ៥ អីណឹងកាលទៅណឹងយុវជននារីយើងនៅអៀន ពេលដែលឈរទទួលណឹងរកកន្លែងបត់ដៃបត់ជើងមិនឃើញទ្រាមអត់អ្នកខ្លះទៅជាស្ទុះខ្លះរឹង កន្ទុះណឹងអស់ហើយស្រីៗអត់ហ៊ានទៅនោមណានៅទទួលម៉ោយប់ហើយខ្លះស្ទុះបញ្ជូនមក មន្ទីរពេទ្យខះខ្យល់ចាប់អត់អីហូបកាលនោះគេមិនដែលមានរបបហូបពេលព្រឹកទេពេទ្យ ចំនួនអ្នកជំងឺច្រើនពេកខ្ញុំអត់បានទៅមើលគេ

យឹមៈ ចុះន្ទីរពេទ្យណឹងមានផ្នែកអីត្រឹមត្រូវទេ?

សេងៈ មាន មានបន្ទប់វះ ថាំល្អ

យឹមៈ ចុះបងធ្វើការនៅពេទ្យណឹងម៉ាថ្ងៃប៉ុន្មានម៉ោង ?

សេងៈ អត់មានម៉ោងអត់មានឈប់ទេ អត់កំណត់បានថាដឹងថាថៃសំរាកអីអត់ងើបម៉ោង៤រហូតដូចថាវាមិនទៀងដែលដូចពេលព្រឹកម៉ោង៤មានអ្នកជំងឺមកគេហៅមកអញ្ចឹងទៅបើមានអ្នកជំងឺធ្ងន់គេហៅមកយើងមក បើជំងឺធម្មតាយើងគ្រាន់តែឲ្យថ្នាំយើងទៅវិញ បើអ្នកជំងឺមកផ្ទួនៗគ្នាអត់បានសំរាកទេ

យឹមៈ ចុះរបៀបរបបហូបចុកអីធូរធារ

សេងៈ បបររមអ្នកជំងឺក៏បបរ បុគ្គលិកក៏បបរ

យឹមៈ ចុះនៅពេទ្យណឹងមានប្រជាជនបែងចែដែរ អ្នកជំងឺប្រភេទណាៗដែរអត់ទេ?

សេងៈ អត់ទេ ១៧ក៏មាន អត់អីទេគេអត់មានបែងចែកវណ្ណៈឋានៈអីទៀតទេ ១៧ក៏ព្យាបាលប៉ុនគេបែងចេះជំងឺស្រាលធ្ងន់ ពិសេសដាក់ដោយឡែកពីគ្នាហើយរបួសដាក់ម៉ាជុំជំងឺដាកម៉ាជុំតែរបបហុបបើគ្រុនចំណីណាដែលត្រូវលាប់អាណឹងគេអត់ឲ្យហូបទេ អ្នករបួសហូមទូទៅទាំងអស់ អាណឹងគេបែងចែក

យឹមៈ នោជាមួយតាសីគេឲ្យធ្វើអីខ្លះទៀត?

សេង: ធ្វើតែពេទ្យដូចជាបើកវគ្គអីគាត់ហៅទៅ ចាក់កម្មាភិបាលៗ ស្គាល់តែភូមិភាគបស្ចឹម និរតី អត់ដែលស្គាល់គេទេ

ឃីម: ចុះបងថាបង្រៀនគេគេបង្រៀនកុមារ?

សេង: ចាំកុមារតូចៗរៀនអក្សររៀនបកប្រែអាយុតែ៧ឆ្នាំគេកំណត់ឲ្យយើងគេបង្រៀនបានហើយ

ឃីម: ចុះបង្រៀនបកប្រែវារៀនបានដែរ

សេង: មានអីស្រួលបកដូចថាលេខចឹង យើងសរសេរឲ្យបាន៦លេខ ហើយបាន៩ខ្ទង់ មុនដំបូងបង្រៀនឲ្យសរសេរលេខដៃយើង ឲ្យគ្រប់៦និងគ្រប់៩កូឡោនទៅ សរសេរចុះមកក្រោម វាចេះប្រើពេលយូរដែរក្មេងតូចៗណឹងសុទ្ធតែក្មេងកម្មាភិបាលប៉ុនពួកណឹងងាប់ អស់ហើយ គេយកមកដាក់ ដេលគេយកពីរអាយុ៦ឆ្នាំ យកអស់អាលឹង

ឃីម: ចុះបងមានដឹងថាហេតុអីបានបងចូលពេទ្យ?

សេង: ថាចង់ចេះហ្នឹងខ្លាចគេចាក់ថ្នាំប្រទ្បុំស្លាប់ព្រោះអីកាលណាខ្ញុំស្លាប់នោភូមិភាគបស្ចឹមមានអ្នណាស្គាល់បើស្រុកខ្ញុំនៅនេះ

ឃីម: ចុះគេជ្រើសចង់ចូលពេទ្យដូចបងដែរ?

សេង: គេជ្រើងគេរើសមកសុទ្ធតែអញ្ចឹងដែរណឹង រើសពីភូមិរើសពីអីមក ។

ឃីម: ប្រធានតំបន់នៅកន្លែងឃុំ តាសោមណឹងបងទៅណាក្រោយពីវែកបាយ?

សេង: ទៅធ្វើព័ទ ។

ឃីម: ចុះប្រធាននារីតំបន់ឈ្មោះអី?

សេង: យាយថែម បងជាតិ បងឃឿនដល់តំបន់ណឹងគេពិនិតទៅវាអត់មានអ្នកពីនិត្យប្រវត្តិរូបធ្វើកងទ័ពដែលត្រូវចេញទៅ គេឲ្យខ្ញុំនោពិនិត្យណឹង ។

ឃីម: ចុះធ្វើកងទ័ពសុទ្ធតែពីនិត្យប្រវត្តិរូបទៀត ចុះគេជ្រើសរើសម៉េច?

សេង: ជ្រើសរើសដូចថា ដូចខ្ញុំចឹងអត់មានម៉ែឪនៅខាងក្នុង កាលណឹងគេបែងចែកខាងក្នុងខាងក្រៅអត់មានចឹងបានគេឲ្យទៅ ដូចខ្ញុំមានពាក់ព័ន្ធពូខ្ញុំនៅខាងក្នុងពូបង្កើតគាត់នៅទល់សព្វថ្ងៃណឹងដែរ គាបាន់សារ៉នកសិកម្មខេត្តតាកែវ

ឃីម: ចុះថារើសវណ្ណៈភាបម៉េច?

សេងៈ មុនដំបូងគេរើស បានជាគេអត់ឲ្យខ្ញុំទៅណឹងមានពូនៅខាងក្នុងហើយខ្ញុំអនុធន សិស្សនណឹងផងហើយឪខ្ញុំកសិករកណ្តាលថ្នាក់លើឪខ្ញុំណឹងគាត់មានដែរណឹងនៅផ្ទះធំៗមិនចឹងទេ ដល ពេល ឪៗ កូនៗទៅចុះកាលណឹងកាលណោះវាបុករុកគ្នាវាប្រណែនគ្នា

យឹមៈ ចុះបងមានដឹងថាគេរើសស្អីខ្លះបែកប្រភេទមនុស្សប៉ុន្មានអីទេ?

សេងៈ អត់ដឹង

យឹមៈ ចុះគោលការណ៍អង្គការហេតុអីបានជាគេយកយុវជនយុវនារីធ្វើបដិវត្តន៍?

សេងៈ អត់ដឹងដែរបើខ្ញុំមកវិញគេវៃតាកែវបែកហើយ ម៉ែខ្ញុំថាឲ្យទៅធ្វើនឹងគេនៅនារីភូមិគេអត់រាប់រកប៉ុនខឹងដែរណឹង

យឹមៈ ចុះបងថាស្គាល់ពេទ្យវ៉ុធណឹងនៅណា?

សេងៈ បងវ៉ុធនៅពេទ្យ១៩០ខ្ញុំអត់ដែលនៅ១៩០ផង ខ្ញុំស្គាល់កាលណឹងបងឃឿន បងប្អូប បងវ៉ុធណឹង ខ្ញុំនៅជាមួយបងឃឿនណឹង បងឃឿននារីតំបន់ ហីខ្ញុំនិរសាគាត់ចេះតែឌុបកង់

យឹមៈ ចុះនិរសាគេឲ្យធ្វើអីខ្លះ?

សេងៈ និរសាដើរតែឌុបវាណឹងដូចថា រៀនអីអត់សរសេរគេណៈតំបន់ចេហអក្សរអីគេសរសេរឲ្យគចំលងឯកសារឲ្យគេ មិនមែននិរសាឥឡូដើរសាឡាប បើមេបញ្ជាការមិនចេះអក្សរផងមិនកូនចោសរសេរឲ្យ

យឹមៈ បងពេទ្យតំបន់៣២ណឹងដែលថាមនាចិនមកបង្រៀនហើយអ្នកណាជាប្រធាន?

សេងៈ ពូគ្រិនណឹង

យឹមៈ ចុះពូគ្រិនណឹងក្រែងឌុកទ័រម៉េទៅរៀនជាមួយបង?

សេងៈ គាត់បង្រៀនខ្ញុំមុនដំបូងពូគ្រីនណឹងគាត់ទៅពី១៩០ជាមួយបងវ៉ុធគេបំបែក គាតត្រូវទៅកំពង់ស្ពឺ ពួកណឹងត្រូវបងសីកេនៅពេទ្យ១៩០

យឹមៈ សី ពេទ្យនៅតាកែវ ឬពេទ្យនៅ១៧មេសា ?

សេងៈ សីនៅពេទ្យ១៩០គាត់នៅជាប់គុកព្រៃញ្ញោដែរសីណឹងប្រពន្ធគាវ់ឈ្មោះបងបូ កាលនេះពូសីនិងពូគ្រិនណឹងសមត្ថភាពប្រហែលគ្នាគេបំបែកទៅកំពង់ស្ពឺៗណឹងអត់មានពេទ្យចុះអ្នក ស្រុកកំពង់ស្ពឺយើដឹងហើយអបឡាំងអីអត់មានអ្នកចេះអក្សរទេ ក្រអ្នកចេះណាស់

យឹម៖ ចុះកាលបងទៅរៀនណឹងមានស្គាល់ឈ្មោះហុងមានទេ នៅពេទ្យ១៧មេសា?

សេង៖ ភ្លេចអស់ហើយ ប៉ុនដែលឮដែរណឹង

យឹម៖ ចុហហេតុអីបានជាគេយកស្រីធ្វើបដិវត្តន៍?

សេង៖ កាលណឹងគេឲ្យទៅវែកហ្នឹងយើងវែកឲ្យទ័បហូបណឹងហ្នឹងលើកកំលាំងទឹកចិត្តយុវជន ឲ្យមានស្មារតីវៃខាំងគេថាអញ្ចឹង គេឲ្យយើងទៅលើកទឹកចិត្តគេ

យឹម៖ ចុះបងមានដឹងថាអង្គការគេប្រើគោលការណ៍ម៉េចខ្លះ

សេង៖ អត់

យឹម៖ ចុះមុននិងចូលពេទ្យអង្គកាកណឹងគេរើលក្ខណាពសម្បត្តិនារីម៉េចខ្លះ?

សេង៖ គេរើសយើងស្លូតបូតសុភាពរៀបសារត្រឹមត្រូវដូចខ្ញុំសំគេឲ្យចូលដែរណឹង

យឹម៖ ចុះជាទូទៅ?

សេង៖ ជាទូទៅគេរើសតាមវណ្ណៈភាពក្រដូចខ្ញុំអនុធនបានជាខ្ញុំសុំគេគេទំរាំឲ្យឲ្យណឹងគេតាមដានយើងទៀតដូចថាគេឲ្យយើងធ្វើអីមួយ យើងរៀនចាក់ថ្នាំបន្ទប់នេះឈ្មោះ ក ខ កាលណាយើងចាក់ទៅប្រតិកម្មអាប់សែយើងទទួលខុសត្រូវហើយខ្ញុំចេះតែខំអត់មានអាប់សែចេះតែឡើងទៅ ហើយណាមួយផ្ទះសំបែងអីអត់មានគិតទេ ម៉ែឪបងប្អូនមិនដឹងទៅណា

យឹម៖ ចុហចំណោះអ្នកគៅរៀនពេទ្យណឹងមើលទៅមានអ្នកចេះអក្សអត់ទេ?

សេង៖ អត់ទេ អត់ចេះ ដូចពេទ្យមឿនអីគេថា ចេះចាក់ៗទៅ អាណឹងយើងនៅបុគ្គលិកកេអត់ឲ្យយើងឡើងទេ បើយើងចេះកេឲ្យយើងឡើងតាម ហើយគេរើសតាមកំរិតចេះដឹងយើដែរ បើយើងចេះគេបង្កើនមុនដំបូងបឋមទី១ទី២ ទំរាំដល់មធ្យមគេវែងស្មេ

យឹម៖ ចុះបងរៀបបឋមដែរ?

សេង៖ រៀនបឋមនៅពេទ្យរៀនបឋមនៅពេទ្យដីឆ្នាំង

យឹម៖ ចុះរៀនបឋមគេឲ្យរៀនអីខ្លះ?

សេង៖ រៀនចាក់រៀនបូមថ្នាំអីណឹង

យឹម៖ ចុះទេពេទុស្សី?

សេង៖ វគ្គមធ្យមហើយ ពេទ្យចំពុះវគ្គមធ្យមដែរពេទ្យពិនិត្យជំងឺ

យឹមៈ ចុះតាមបងដឹងបងរៀនបានតែម៉ាវគ្គឹង៥ខែទេ?

សេងៈ ៥ខែ ក្រោយមកទៅកេទេសបានតែ២ខែដល់ហើយបែករញ៉េរញ៉ៃកេចាប់ណឹង

យឹមៈ ឆ្នាំណាទៅក្រោយពីរខែ?

សេងៈ ៧៧

យឹមៈ ចុះទោណឹងមានឃើញចននៅពេទ្យរុស្សី?

សេងៈ មាន ជនាញការចិន ចិនបង្រៀនតែមូលវិទ្យាសាស្ត្រ

យឹមៈ ចុះមានដឹងថាអ្នកណាគេរដ្ឋមន្ត្រីពេទ្យ ខាងសុខាភិបាល?

សេងៈ អត់ដឹងទេ

យឹមៈ ចុះគាជូនចៀនគាត់ធ្វើអី?

សេងៈ គាត់អ្នកឯកទេសវះកាត់អត់ដឹងធ្វើអីទេ

យឹមៈ ចុះអៀងធារិទ្ធ

សេងៈ ណឹង ខាងនយោបាយ

យឹមៈ ចុះដឹងថាគាត់មានឋានៈអីទេ?

សេងៈ អត់ដឹង

យឹមៈ ចុះគេបង្រៀនគេប្រើវិធិពិសោធន៍អី?

សេងៈ ដូចថាបង្រៀនយើងចង់ដឹង រៀនដាក់ស្តែងមូលវិទ្យាសាស្ត្រដូចថាមីអូនឯងគេចាក់ ចំណុច លូិតភ្នែកគេចាក់ទៅ កៀនត្រចៀកណឹងបីបួនកន្លែង ម៉ាកញ៉ឹងក ពិសោធន៍បុគ្គលិកដូចគ្នា ណឹង ឈឺ អត់មានជំងឺអីដងគេពិសោធន៍ចឹងហ្នង អានេះត្បាល់តិចអា នោះត្បាល់តិច ដូច ខ្ទុយ ខាំ ដែលថាយំ ស្រក់ទឹកភ្នែក អានេះពាល់តិច ឈឺដូចខ្ទុយទិចចឹង

យឹមៈ ចុះគេថាអត់ឈឺទេ?

សេងៈ អត់ឈឺម៉េច បើខ្ញុំអត់ឈឺអីដងគេយកមកចាក់ ស្រក់ទឹកភ្នែកម៉ាត់ អានេះម្តងម្នាក់ ដូចថាគេចង់ចេះគេមកមូលអាណឹងតែពាល់ឈឺ ហើយបើអត់ពាល់អត់ឈឺទេចាក់ចូល អត់អី ទេ ទុកណឹង បើម្នាក់ចឹងៗគេចង់ដឹងម៉េចវិញ ដល់ត្បាល់តៅវាមានប្រសិទ្ធភាពអីវាឈឺអត់ វាប៉ះអី

យឹមៈ ចុះចិនជាអ្នកបង្រៀនផ្ទាល់?

សេងៈ ចិនអ្នកចាក់ហើយឲ្យសិក្ខាកាមយើងទៅធ្វើចំណុចគេ

យឹមៈ ចុះអ្នកបកប្រែឈ្មោះអី?

សេងៈ អត់ទេចិនណឹងចេះខ្មែរដែរណឹង

យឹមៈ ចិនណឹងជនជាតិចិនមកពីស្រុកចិន ឬនៅស្រុកខ្មែរ?

សេងៈ ខ្មែរណឹង ចេះខ្មែរ

យឹមៈ ចុះក្រៅពីពិសោធន៍ណឹងមានពិសោធន៍អីទៀតទេ?

សេងៈ ដូចថា វះមនុស្ស រៀនវះមុនដំបូងអាណឹងនៅពេទ្យចំពុះវន្ត័ សុទ្ធតែថ្មីដូចគ្នាវះមនុស្ស ហ្នឹងគេថាខ្លាំង មនុស្សរស់ណឹង គិតទៅសាហាវវះមុនដំបូងមានីវាខឹងអាណឹងពេក ចុះទំលាក់គ្រាប់បែកៗម៉ាឆ្នាំនឹងមិនដឹងប៉ុន្មានដងតែពួលខ្ញុំរវល់តែរត់ មិនដឹងឈ្មោះអីទេកាលណឹងមានគេអូនៅបាតដៃគេនោះ គេបក់ហៅមក ដល់ហើយចង់ដឹងមើកថាមានអត់ ដល់វះទៅមាន ប៉ិណណឹងហើយក្រហមនៅបាតដៃ មានមែន ដល់អញ្ចឹងថាប្រថុយថាវះហើយដល់ហើយគេបង្រៀនវះពោះ គេចងមុខនិងចងខ្លួនជាប់ដើមឈើគេអត់មាន ចាក់ថ្នាំ សន្ទប់អីទេអាណឹងវះពិសោធន៍មុនដំបូងឲ្យដឹងថាវះមុនដំបូងដល់ទ្រាប់អីៗចឹងទៅណា ពេលឃើញគេអីយើងប្រថុយវះពោះទៅព្រោះយើងអត់ទាន់វះពោះស្រួលបួលផង ហើយពូកាន់ណឹងថាវះពោះទៅនៅឈរមើលជាមួយគ្នាណឹង វះមុនដល់ស្រទាប់ ដំបូងមិនខ្វាញ់ ហើយស្រទាប់សាច់ បាតពោះណឹងទៀត វានៅដឹងរហូតទាល់តែកាត់បេះដូងប៉ិតបានឈប់និយាយ

យឹមៈ វានិយាយម៉េចខ្លះ?

សេងៈ វានិយាយថាបងអើយកុំធ្វើបាបខ្ញុំៗ ខ្ញុំមានទៅប៉ះពាល់អីគ្រាន់តែឈរមើល

យឹមៈ ចុះបងមានអារម្មណ៍អាណិតទេ?

សេងៈ អាណិត ដល់ហើយថ្លើមណឹងគេយកទៅឆាហូបទៀត

យឹមៈ ឆ្នាំណាកាលណឹង?

សេង: ឆ្នាំ៧៦ណឹង ចាប់បានមានអ្នកក្បត់ មិនដឹងអង្គភាពណាណាទេ ប៉ុនកងទ័ពគេបញ្ជូនមកថាឲ្យពេទ្យយកមកវិនិច្ឆ័យចុះពេទ្យវាខឹងដែរព្រោះអី អាណឹងវាហៅទំលាក់ គេខឹងថាបើបានស៊ីឆៅ

ឃីម: ដល់ពេលវះទោឃើញម៉េចខ្លះ?

សេង: កាលណឹងថ្ងៃល្ងាចព្រលប់ៗ វះឃើញស្រទាប់សាច់ដុំឃើញខ្លាញ់ វះតែពោះនិងដៃដល់កាត់បេះដូងបានឈប់ស្រែក

ឃីម: ចុះពោះមានចេញពោះវៀនអីទេ?

សេង: ចេញចុះមានអីយើងមានប្រដាប់ខ្ទប់ឈាមហូរសស្រាក់ដូចនេះចឹងមិនមេនយើងវះអ្នក ជំងឺយើងមានអិប្រដាប់ត្រឹមត្រូវណាយើងអត់ យកទៅពិសោធន៍ ពូកាន់ណឹង គេចាប់បាត់អស់ហើយយកថ្លើមណឹងឆាហូប ឆាហូបណឹងគេថាបើអ្នកណាអត់ហូបមិនមែនបដិវត្តន៍ ទេក្បត់ហើយ ប៉ុនខ្ញុំអត់ហ៊ានហូបទេ ខ្ញុំអង្គុយកៀនខាងគេអញ្ចឹង គេឲ្យមកខ្ញុំទំលាក់ ខ្ញុំស្ទៀកខោទៅដីទៅ អ្នកណាហ៊ានហូម គេថាឆាទៅលោត ខ្ញុំអត់ហ៊ានហូបទេ កាលណឹងខ្វះអីស្រាកាលបែកភ្នំពេញហើយ ស្រាល្អ ប្រុសៗគេផឹកទៅខ្ញុំអត់ហ៊ានទេ ស្រិបីបួននាក់អត់ហូបទេ

ឃីម: ចុះពេលបងរៀនពេទ្យគេមានប្រាប់ថាម៉េចដើម្បីឲ្យក្លាយជាគ្រូពេទ្យល្អ?

សេង: គេប្រាប់ឲ្យយើងខិតខំយកចិត្តទុដាក់ថៃអ្នកជំងឺ កាលណោះមានពិទ្ធុមានតែចាកស្ដែង គេធ្វើឲ្យអ្នកជំងឺស្រឡាញ់

ឃីម: មុិញបងនិយាយរឿងសីលធម៌ថានៅក្នុងពេទ្យមានអ្នកខុសសីលធម៌បើអង្គការដឹងគេដាក់វិន័យម៉េច?

សេង: គេយកទៅបាត់ទៅមិនដឹងយកទៅណាទេ គេយកទៅដាក់កន្លែងដត់លំគេទៀត គេមិនទុំឲ្យនៅក្នុងមន្ទីរពេទ្យណឹងទេ គេដកចេញ

ឃីម: ចុះគេមានដែលលើកលែងទោសគេអ្នកខុសសីលធម៌?

សេង: បើយើងគាំត្រគ្នាយើងថាបីបួននាក់ ថាម្នាក់ណឹងអត់ទេ អាណឹងគេលើកលែង ហើយភាគច្រើន អាណឹងភាគច្រើនតែគេនៅតាមដានទៀត

ឃីមៈ ចុះយើងមានសិទ្ធអីខ្លះលើអ្នជំងឺ បើយើងជាគ្រូពេទ្យម្នាក់?

សេង៖ អ្នកជំងឺ យើងឲ្យហូបចុកលើយើងចាក់ថ្នាំ ដល់ម៉ោងក៏យើងចាក់ឲ្យគេ

ឃីមៈ ចុះអ្នកជំងឺវិញមានសិទ្ធអីតវ៉ាអីទេ?

សេង៖ មាន បើថាមិនចេះអត់ ជូនណាគេធាក់ចឹងទៅបើគេចរូចគេចទៅបើមិនរួចដួលផ្ងារទៅចុះពេទ្យការណឹងមានលុយណា

ឃីមៈ ចុះអង្គការមានផ្តល់សិទ្ធអីខ្លះ ដល់យើងជាគ្រូពេទ្យ?

សេង៖ អត់មានផ្តល់អី គ្រាន់ដើរហើអត់មានដើរទេកាលនៅធ្វើពេទ្យណឹង នៅមន្ទីរណឹងគឺនៅហើយហូបចុកអីរបបដូចគ្នាទាំងអស់បើថាបបរដូចគ្នា

ឃីមៈ ចុះអង្គការមានយកចិត្តទុកលើបុគ្គលិពេទ្យទេ?

សេង៖ អត់ដែលមានរបបអីពិសេសទេអត់ហូបតែមួយគ្នដេកនៅជាមួយគ្នាខោអាវអីណឹង ម៉ាឆ្នាំគេបើកឲ្យម្តង ស៊ីចុកអីដូចអ្នកជំងឺមានតែយ៉ាប់ជាងអ្នកជំងឺផង

ឃីមៈ ចុះបើអ្នកជំងឺចូលមកប្រភេទវណ្ណៈផ្សេងគ្នាយកចិត្តទុកដាកដាង?

សេង៖ យកចិត្តទុកដាក់ហើយអ្នកធំគេណឹង បើថាកូនងើតមួយត្រូវប្រើថ្នាំអស់ប៉ុន្មាន អ្នកទូទៅយើងប្រើតែបីម្តុលដល់ប្រពន្ធកម្មាភិបាលយើងប្រើ៦ហើយ ឆាប់ជាឆាប់បានទៅផ្ទះគេវិញគេទៅធ្វើការ តែបើគេឲ្យនៅបន្ទប់ជាមួយគ្នាអត់បែងចែកទេនៅពេទ្យចំពុះវ័ន្តមិនសូវអីទេកំពង់ស្ពឺ ប៉ុនពេទ្យខ្ញុំណឹងតាស៊ីចុះជាប់គាត់អត់មានបែងចែកទេ ១៧មេសាពួកណឹងគេហៅកងចល័ត អត់មានទេ គាត់យកចិត្តទុកដាក់

ឃីមៈ ចុះបងធ្លាប់បំរើអង្គការ មានធ្លាប់ទទួលផលប្រយោជន៍អីទេ?

សេង៖ អត់អាលីង?

ឃីមៈ ចុះបងយល់ម៉េចដែរពីមាគ៌ាអង្គការ ពេលបងឃើញអង្គការចាប់មនុស្សអីណឹងតើមាគ៌ាណឹងល្អឬងាក្រក់?

សេង៖ មិនល្អ បើមិនឃើញក្បត់អីមួយផងជាក់ស្តែងក្បត់ថាធ្វើសកម្មភាពចេះមួយចេះពីរចាក់ថ្នាំសំលាប់អ្នកជំងឺក៏អត់ ហើយចេះតែចោទទៅដូចតាស៊ីអីណឹង ថាគាត់សុទ្ធតែខូចសីលធម៌

ជាមួយនារី ៥០ ៦០នាក់ ហាសិបណាបើគាត់អត់មានប្រមាត់ផងអានឹងថាជាក់ស្តែង ឲ្យជឿខ្ញុំអត់ជឿ

ឃីមៈ ចុះគាត់មានខុសសីលធម៌តាមចំលើយសារភាពអត់

សេងៈ អត់ទេ ខុសអីបើគាត់បងឪខ្ញុំទៀត គាត់អាយុ ៥០ជាងហើយហើយគ្មានកូនអីមួយផង

ឃីមៈ ចុះបងផ្ទើពេទ្យមានសេរីភាពមានឲ្យដើរទៅណាទេ?

សេងៈ អត់ទេនៅតែក្នុងមន្ទីរពេទ្យ អត់ហ៊ានសុំទេខ្លាចគេ កាលនៅជាមួយតាស៊ីនាំមក លេងកាលម៉ែខ្ញុំនៅអង្គរមកបានម៉ាដងណឹងកាលឆ្នាំ ៧៧ ក្រៅពីណឹងអត់ដែលមកផ្ទះសោះ

ឃីមៈ ចុះកាលគេចាប់តាស៊ីណឹងឆ្នាំ៧៧ ឬ៧៨?

សេងៈ ៧៨ ខែ៤ ខ្ញុំរបាំត់របាំយមកសាធារណៈការណ៍អីណឹង ៧៨

ឃីមៈ ចុះបងមានបាទៅឃើញផ្ទាល់ភ្នែកនៅភ្នំបាសិត ថាគេចាប់ដាក់ណឹងទេ?

សេងៈ អត់មានបានទៅដល់ណឹងទេ គ្រាន់តែគេថាដឹកដាក់ភ្នំបាសិតពួកខ្ញុំណឹងគេដឹកដាក់ណឹង ៤ឡានប៉ុនអត់មានឃើញ ប៉ុនលផ្នែកក៏អត់ឃើញដែរគ្រាន់តែឮសូសំលេងយប់ឡើងស្រែកពេញទាំងអស់ ខ្ញុំមានសិទ្ធអីចូលនឹងគេ

ឃីមៈ ចុះបងមានដែលមានអារម្មណ៍ថា ពេលគេងយប់ទៅបងមានដែលយល់សប្តិ

សេងៈ ចាំ ដែលភ័យខ្លាច

ឃីមៈ ចុះខបមាថាបង្កើតតុលាការកាត់ទោស បងចង់ឲ្យមានតុលាការ?

សេងៈ អត់ដឹង

ឃីមៈ ចុះបងដែលឮពាក្យខ្មែរក្រហម ឮតាំងពីឆ្នាំណា?

សេងៈ ជីមិនឮ ឮតាំងពីឆ្នាំ ៦៦ ៦៧យូរ

ឃីមៈ ចុះពាក្យប៉ុល ពត ?

សេងៈ ទើបឮ បែក៧៥ ហើយ ឃើញប៉ុល ពត ៧៧ហើយណឹង

ឃីមៈ បងមានដែលឈឺចាប់អីជាងគេខ្លាំងទេ ក្នុងសម័យប៉ុល ពត?

សេង៖ ឈឺចាប់ផ្លូវចិត្តមិនដេលសប្បាយមិនដែលស្រណុក អីគេ ខំតស៊ូពិបាកអីចង់ងាប់ អត់បាន លទ្ធផលអី ចុងបញ្ចប់គេធ្វើចឹងវ៉ាន់

ឃីម៖ ចុះបងឈឺចាប់ចឹង បងមានចង់បានសំណាងអី ឬសងសឹកមកវិញ

សេង៖ អត់ទេ កាលមកជំនាន់នេះក៏ខ្ញុំមានការពិបាកជាងគេដែរ ពិ៧៩ណឹងមក មកដល់បាត់ដំ ទទេឪខ្ញុំនេះគេយកដាក់គុកកោះអណ្តើកព្រោះគាត់ធ្វើសេដ្ឋកិច្ចពេទ្យ ខ្ញុំគ្រាន់មកដល់គេឲ្យរៀ ននៅអង្គរសោមទៅរៀននយោបាយ ៧៩ខែ៧ គេឲ្យទៅរៀនខាងជើងអង្គសោម ដល់ ហើយ ពួមួយមកពីបូព៌ាគាត់រៀងក្មេងស្អមស្តើង គាត់សួរខ្ញុំថាចុះមិត្តឯងធ្វើអីបានជាគេមក ណឹងអ្នកខទ្ទេសនាមឯកសារណឹង ខ្ញុំថាធ្វើពេទ្យគេឲ្យមកដែរនេះ ទៅបង្រៀនណឹងកន្លះខែ គេថាពេទ្យពីបីនេះឲ្យទៅផ្ទះវិញទៅគ្មានស្អីទេ ភូមិរាយការណ៍ឲ្យទៅ

ឃីម៖ បងអត់ថាជួន ជឿនណឹងមានឋានៈអីទេ

សេង៖ អត់ ដឹងថាគាត់ជាអ្នកឯកទេសវះកាត់ រៀនដាក់ស្តែងនិងរៀនទ្រឹស្តី ដូចថាយើងរៀនម៉ោ ថ្ងៃយើងរៀនសរីរាង្គតាសាគណឹងជំងឺទូទៅ ដូចថារបេងពូអុិនសូកានមកបង្រៀន ដល់ឆ្នប បងសីណឹងគាត់មកបង្រៀនប្រពន្ធតជឿនណឹងគាត់មកខាងពិសោធន៍ឈាមទៅ យើងរៀន តាម គេដាក់តាមពេលគ្នាដែរណឹង

ឃីម៖ ចុះមើលជួនជឿនណឹងជាអ្នកបដិវត្តន៍ចំបុ?

សេង៖ គាត់ដូចមិនអីដែរ ជាមួយសិក្ខាកាមគាត់អត់មានឆេីងឆ្នៃទេ អត់មានអីទេ

ឃីម៖ ចុះមើទៅប៉ុលពតម៉េច?

សេង៖ គាត់ដែលមិននិយាយអី និយាយជាមួយគាត់អត់ដែលមានពាក្យល្អទេ

ឃីម៖ ចុះគេអ្នកដទៃប្រើពាក្យអញ្ចឹងដែរ

សេង៖ គេអញ្ចឹងដែរណឹងហូបចុកអីកអញ្ចឹងដែរកន្លែងគាត់មិនខ្វះទេ ស្អីៗគ្រប់មុខតែយើងគ្រប់គ្នា អត់ទេ ចំណឹថាដ្ឋៃឈើវិញទិញពេញទូពេញថាស

ឃីម៖ ចុះគាត់មានដែលហៅបុគ្គលិកអីហូបទេ?

សេង៖ អត់ទេ សល់អីយើងមានសិទ្ធអីយើងអត់ហ៊ានយក សល់អង្ករក្សគាត់លើកទៅយើងអត់ ហ៊ានទៅជិតទេ

យឺមៈ ចុះរៀបបាយរៀបទឹកសុទ្ធតែភ្ជក់?

សេងៈ រៀបបាយទឹកអីគេភ្ជក់ អង្ករក្បៀនៅយាមក្នុងបន្ទប់ពេលបាយគេទៅដើរភ្ជក់ក្នុងឆ្នាំង

យឺមៈ បងអរគុណច្រើន ហើយ

យឺមៈ ចុះបងឈ្មោះអី?

សេងៈ ឈ្មោះ សៀង សេង

យឺមៈ នៅភូមិអី?

សេងៈ ភូមិទទឹងថ្ងៃ

យឺមៈ ឃុំ

សេងៈ ជាងទងស្រុកត្រាំកក់

យឺមៈ អរគុណច្រើន